# មិត្តនគរបាល

POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្តី

លេខ ១០៣/ មករា-កុម្ភៈ / ២០២២

## អរគុណសន្តិភាព










យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

**នាយកគ្រប់គ្រង**

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

**និពន្ធនាយក**

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

**និពន្ធនាយករង**

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា



**យកព័ត៌មាន និពន្ធ**

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)
-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ
-អនុសេនីយ៍ឯក គន សេរី

**ថតរូប**

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)
-អនុសេនីយ៍ឯក ស្រ៊ី ឈុនឡេង
-អនុសេនីយ៍ឯក លន់ ឈាងសេង
-អនុសេនីយ៍ឯក ព្រំ ចាន់តារា

**ចែកផ្សាយ**

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)
-វរសេនីយ៍ត្រី សុន សៀង

**រចនាទំព័រ**

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក អ៊ុន ពិសិទ្ធ

**ពិនិត្យអក្ខរាវិរុទ្ធ**

-វរសេនីយ៍ទោ ញឹម ហឿន (ប្រធានក្រុម)
-អនុសេនីយ៍ឯក វ៉ាន់ វិបុល

**កីឡា និងសិល្បៈ**

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)
-អនុសេនីយ៍ឯក មុត សីហា







# មាតិកា

## ព័ត៌មានថ្នាក់ដឹកនាំ


១-ក្រសួងមហាផ្ទៃ បូកសរុបលទ្ធផលការងារ....................០១
២-សម្ដេចក្រឡាហោម អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់........០៧
៣-សេចក្ដីប្រកាសព័ត៌មានអំពីលទ្ធផលកិច្ចប្រជុំ ...........១១
៤-សម្ដេចក្រឡាហោម ឲ្យតែមានការតស៊ូព្យាយាម.........១៣
៥-សម្ដេចក្រឡាហោម គាំទ្រគំនិតផ្ដួចផ្ដើមរបស់.............១៥
៦-ឯកឧត្តម សក់ សេដ្ឋា អញ្ជើញពិនិត្យវឌ្ឍនភាព.........១៧
៧-កិច្ចប្រជុំដកពិសោធន៍ការងារគ្រប់គ្រងវត្ថុមាន................១៩
៨-អនុស្សរណៈ និងកិច្ចព្រមព្រៀងចំនួន ២ ត្រូវបាន .........២១
៩-សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីគោរមងារ ឧកញ៉ា ............២៣
១០-ប្រគល់រថយន្ត Pick Up ឆ្នាំ២០២២ ចំនួន ១៩គ្រឿង.....២៥
១១-ប្រកាសចូលកាន់មុខតំណែងនាយក-នាយករង..........២៧
១២-កិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាព..............២៩
១៣-សម្ដេចក្រឡាហោម អនុញ្ញាតិឲ្យឯកអគ្គរដ្ឋទូតថ្មី......៣១
១៤-ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ..............៣៣
១៥-កិច្ចប្រជុំស្ដីពីការត្រៀមរៀបចំធ្វើសន្និសីទអាស៊ាន..........៤៣
១៦-អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំ.................៤៤
១៧-ប្រគល់-ទទួលទីស្នាក់ការប៉ុស្ដិ៍នគរបាលការពារ..............៤៧


## អត្ថបទស្រាវជ្រាវ


១-មហាសង្ក្រាន្តឆ្នាំខាល ចត្វាស័ក........................................៤៧
២-ការរាតត្បាតវីរុសបំលែងថ្មី អូមីក្រុង OMICRON.....................៥១


## សកម្មភាពសមាគមមិត្តនគរបាលជាតិកម្ពុជា


១- ប្រគល់ថវិកា ស ម ន...................................................៥៩


## កំណាព្យ


១-បណ្ដាំស្លឹកចាស់........................................................៥៤


## ប្រលោមលោក


១- បំភ្លេចមិនបាន........................................................៦១




# ក្រសួងមហាផ្ទៃ បូកសរុបលទ្ធផលការងារឆ្នាំ

## ★ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ និង

បន្ទាប់ពីដំណើរការអស់រយៈពេលមួយថ្ងៃកន្លះ (ថ្ងៃទី២២ ដល់ព្រឹកថ្ងៃទី២៣ ខែកុម្ភៈឆ្នាំ២០២២) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រួចមកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ បានរៀបចំពិធីបិទ នារសៀលថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។**

នៅក្នុងរបាយការណ៍លទ្ធផលការងារឆ្នាំ២០២១ ដែលអានដោយ ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ គត្ថិ** អគ្គលេខាធិការក្រសួងមហាផ្ទៃ ពាក់ព័ន្ធកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស បានបញ្ជាក់








# ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ផ្តល់អនុសាសន៍ក្នុងពិធីបិទសន្និបាត





រាយការណ៍ដឹងថា ៖

-បទល្មើសព្រហ្មទណ្ឌ ជារួមកើតឡើង ៣.០៥៥/៣.២៥៤លើក ថយ ១៩៩លើក ស្មើ ៦% (បទឧក្រិដ្ឋ ៥៨៩/៦៨២ ថយ ៩៣លើក ស្មើ ១៤% និងបទមជ្ឈិម ២.៤៦៦/២.៥៧២លើក ថយ ១០៦លើក ស្មើ ៤%) ស្លាប់ ២១៣នាក់ របួស ៩៨០នាក់ រងគ្រោះ ១.៥៨២នាក់ បាត់បង់រថយន្ត ៦១គ្រឿង ម៉ូតូ ២៩៧គ្រឿង រួមទាំងសម្ភារៈ មាស ប្រាក់ មួយចំនួន ។ បើកកិច្ចប្រតិបត្តិការបង្ក្រាបបាន ២.៨៥៤ករណី ស្មើ ៩៣% ឃាត់ខ្លួន ៤.០៥៦នាក់ (មានផ្ទុកសារធាតុញៀន ១.៥១៩នាក់ ស្មើ ៣៧%) ក្នុងនោះ បទឧក្រិដ្ឋ ៥៤១ករណី ឃាត់ខ្លួន ៧៨៧នាក់ និងបទមជ្ឈិម ២.៣១៣ករណី ឃាត់ខ្លួន ៣.២៦៩នាក់ ។ អនុវត្តដីកាឆ្នាំចាស់ សរុប ២៦៨ដីកា

០៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា











តមកពីទំព័រ ០២

**ក្រសួងមហាផ្ទៃ បូកសរុបលទ្ធផល...**

មនុស្ស ២៦៧នាក់ (បទខុក្រិដ្ឋ ៦០ដីកា មនុស្ស ៦១នាក់ និង បទមជ្ឈិម ២០៨ដីកា មនុស្ស ២០៦នាក់)។ វត្ថុតាង និងជនល្មើស ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។ កត់សម្គាល់៖ បទល្មើសដែលថយចុះមាន លួចមានស្ថានទម្ងន់ ឃាតកម្ម វាយតប់ធ្វើបាប បរិហារកេរ្តិ៍ ជាដើម ... វិលោភសេពសន្ថវៈ បង្ខាំងមនុស្សដោយខុសច្បាប់ ជំរិតយកប្រាក់ បង្ខាំងមនុស្សខុសច្បាប់ ជះទឹកអាស៊ីត បោក និងបង្កគ្រាប់បែក លួចឆក់ ឆបោក-វិលោភទំនុកចិត្ត បំពានទាងផ្លូវភេទដទៃទៀត ប្រើអាវុធខុសច្បាប់ និងក្លែងឯកសារសាធារណៈ ។

-បង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់បាន ៥.៩៧៤ករណី ឃាត់ខ្លួន ១៧.៦៧២នាក់ ស្រី ៧៣៦នាក់ ក្នុងនោះជនបរទេស ២២៨នាក់/១៥សញ្ជាតិ ស្រី ១៥នាក់ និងអនុវត្តដីកា ៤៤៤ដីកា មនុស្ស ៤៨០នាក់ ស្រី ២៣នាក់ ។ រឹបអូសវត្ថុតាងបាន៖ សារធាតុញៀនគ្រប់ប្រភេទសរុប ៣.៥៤៨,១៣គ.ក្រ សារធាតុគីមីផ្សំផ្សាំង ១តោន កញ្ឆាក្រៀម ១០៧,៤៩៤ គ.ក្រ ដើមកញ្ឆា ១១៨.៥០៥ដើម អាវុធវែង ៣ដើម ខ្លី ២០ដើម រថយន្ត ១១៦គ្រឿង ម៉ូតូ ១.៧៥១គ្រឿង ទូរស័ព្ទ៥.៥៥៦



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល













គ្រឿង ជញ្ជីង ៣៦០គ្រឿង ព្រមទាំងឧបករណ៍វេចខ្ចប់មួយចំនួនទៀត ។ វត្ថុតាង និងជនល្មើសត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។ កត់សម្គាល់៖ បង្ក្រាបករណីធំៗ( ចាប់ពី ១គ.ក្រឡើង ជាក្រុមដែលមានបណ្តាញចាត់តាំង) បានចំនួន ៤៤ករណី ស្មើ ៤១ក្រុម ឃាត់ខ្លួន ៩៩នាក់ ស្រី ១៦នាក់ ដកហូតបានសារធាតុញៀនសរុប ១.៧៣៤គ.ក្រ និង ៥៩៩,៤៧ក្រាម ។

-បង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបាន ៣០០ករណី ឃាត់ខ្លួន ៤៤០នាក់ ស្រី ៤២នាក់ ជនបរទេស ៩នាក់ កសាងសំណុំរឿងបញ្ជូនទៅតុលាការ និងរំដោះជនរងគ្រោះបាន ១.១០៧នាក់ (បញ្ជូនទៅសង្គមកិច្ច ៣២នាក់ និងប្រគល់អោយអាណាព្យាបាលគ្រប់គ្រងវិញ ១.០៧៥នាក់)ក្នុងនោះអំពើជួញដូរមនុស្ស ១៩៣ករណី ឃាត់ខ្លួន ៣២៤នាក់ ស្រី ២៣នាក់ ជបរទេស ៧នាក់ រំដោះជនរងគ្រោះបាន ៩៥៧នាក់ និងអាជីវកម្មផ្លូវភេទ ១០៧ករណី ឃាត់ខ្លួន ១១៦នាក់ ស្រី ១០នាក់ ជនបរទេស ២នាក់ រំដោះជនរងគ្រោះបាន ១៥០នាក់ ។ **កត់សម្គាល់៖** បានសហការជាមួយក្រសួង-ស្ថាប័ន ទាំងក្នុង និងក្រៅប្រទេស ជួយសង្គ្រោះជនរងគ្រោះ និងបញ្ជូនត្រលប់មកកម្ពុជាវិញ ចំនួន ១៩១នាក់ ស្រី ១៨១នាក់ (មកពីប្រទេសចិន ១៨០នាក់ ស្រី ១៧៩នាក់ ឥណ្ឌូនេស៊ី ១ នាក់ ម៉ាឡេស៊ី ១០នាក់)។

-បង្ក្រាបក្រេងទំនើងបាន ១.០៤៧លើក ថយ ៤៤៨លើក ឃាត់ខ្លួន ២.៣៨៧នាក់ ស្រី ៧២នាក់ ក្នុងនោះ កសាងសំណុំរឿងបញ្ជូនទៅតុលាការ ៥៧៧ករណី/១.០២៤នាក់ ស្រី ២០នាក់ (ពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ និងគ្រឿងញៀន) និងអប់រំណែនាំ ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព ៤៧០ករណី/១.៣៦៣នាក់ ស្រី ៥២នាក់ ។

-បង្ក្រាបល្បែងស៊ីសងបាន ១.៣៨៤

☞ ០៥



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ០៤

**ក្រសួងមហាផ្ទៃ បូកសរុបលទ្ធផល...**

ករណី ឃាត់ខ្លួន ៣.៩៦០នាក់ ស្រី១.៧២២នាក់ ក្នុងនោះបញ្ជូនទៅតុលាការ ២២៦ករណីមនុស្ស ៧៨៦នាក់ ស្រី ១៩៥នាក់ រួមទាំងរថយន្ត ២៤គ្រឿង ម៉ូតូ ៤៥៨គ្រឿង និងវត្ថុតាងមួយចំនួនទៀត និងអនុវត្តវិធានការរដ្ឋបាល១.១៦២ករណី មនុស្ស ៣.១៧៤នាក់ ស្រី ១.៥២៧នាក់ ។

-បង្ក្រាបបទល្មើសសេដ្ឋកិច្ចបាន ៤១៤លើក ក្នុងនោះបង្ក្រាបដាក់ស្តែង ៣១៧លើក (ម្ចាស់ការបង្ក្រាប ៣៤លើក) និងដោយស៊ើបអង្កេតស្រាវជ្រាវ ៩៧ករណី (ម្ចាស់ការបង្ក្រាប ២៣លើក) ឃាត់ខ្លួនជនសង្ស័យបានចំនួន ១១៧នាក់ ស្រី ១នាក់ ជនបរទេស ២នាក់ (បញ្ជូនទៅ តុលាការ ២៣នាក់ ស្ថាប័នជំនាញពាក់ព័ន្ធ ៧០នាក់ ស្រី១នាក់ និងអប់រំណែនាំ ២៤នាក់ ជនបរទេស) ។ ករណីដែលបង្ក្រាបបានភាគច្រើនជាបទល្មើស នាំចូលទំនិញគេចពន្ធ និងអាហារខូចគុណភាព បទល្មើសព្រៃឈើ បទល្មើសជលផល រំលោភកម្មសិទ្ធិបញ្ញា និងចរាចរណ៍ ឱសថក្លែងក្លាយ។ល។

នៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារប្រឡងប្រណាំងអនុវត្តគោលនយោបាយ "**ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព**" ពាក់ព័ន្ធវិស័យជំនាញក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដែលអានដោយ ឯកឧត្តម សន្តិបណ្ឌិត **តេជ សាមឌ្យ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានបញ្ជាក់អោយដឹងថា៖ ឆ្លងតាមការពិនិត្យវាយតម្លៃអំពីសភាពការណ៍ កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស និងលទ្ធផលចាត់តាំងអនុវត្តគោលនយោបាយ"**ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព**" នៅទូទាំងប្រទេស ក្រុមប្រឹក្សាប្រឡងប្រណាំងបានកំណត់នូវចំណាត់ថ្នាក់ ឃុំ-សង្កាត់ទាំង ១.៦៤៦ឃុំ-សង្កាត់ ដូចខាងក្រោម៖

លទ្ធផលប្រឡងប្រណាំងតាមនិយាមកំណត់ទាំង ៥ ៖

•**ប្រភេទ១**: មាន ១.១៤៥ឃុំ-សង្កាត់ ស្មើ ៦៩,៥៦%( ថយ ១៦ឃុំ-សង្កាត់ ស្មើនឹង ១%) ឃុំ-សង្កាត់មានសុវត្ថិភាព ៦៨៥ ឃុំ-សង្កាត់ ស្មើ ៤១% ថយ ៨ ឃុំ-សង្កាត់ ស្មើ ១% ។

•**ប្រភេទ២** : មាន ៤៥៩ ឃុំ-សង្កាត់ ស្មើ ២៧,៨៨% ( កើន ៣២ ឃុំ-សង្កាត់ ស្មើនឹង ៧%)

•**ប្រភេទ៣** : មាន ៣៦ ឃុំ-សង្កាត់ ស្មើ ២,១៨% (ថយ ១៨ ឃុំ-សង្កាត់ ស្មើនឹង ៣៣%)

-គ្មានចំណាត់ថ្នាក់ : មាន ៦ ឃុំ-សង្កាត់ ស្មើ ០,៣៦% ( កើន ២ ឃុំ-សង្កាត់) របាយ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ការណ៍បានបញ្ជាក់ឱ្យដឹងទៀតថា៖ រយៈពេល១ឆ្នាំកន្លងទៅ ថ្វីបើប្រទេសកម្ពុជាបាននឹងកំពុងតស៊ូយ៉ាងស្វិតស្វាញក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ និងគ្រោះធម្មជាតិយ៉ាងណាក្តី ក៏ប៉ុន្តែការចាត់តាំងអនុវត្តគោលនយោបាយ "**ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព**" នៅតែដំណើរការយ៉ាងសកម្ម ផុលផុស និងទទួលបានការចូលរួមគាំទ្រពីគ្រប់មូលដ្ឋាន ជាពិសេសនោះ គឺថ្នាក់ដឹកនាំគ្រប់ថ្នាក់ ក្រុមការងាររបស់រាជរដ្ឋាភិបាល និងអាជ្ញាធរដែនដីនៅមូលដ្ឋានផ្ទាល់ បានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយអប់រំអំពីគោលនយោបាយ និងវិធានការនានា របស់រាជរដ្ឋាភិបាល ព្រមទាំងបានចាត់វិធានការចេញជួយសង្គ្រោះប្រជាពលរដ្ឋពីគ្រោះធម្មជាតិ និងបង្ការទប់ស្កាត់បានទាន់ពេលវេលាមិនឲ្យជំងឺរាតត្បាតរីករាលដាលក្លាយជាមហន្តរាយធ្ងន់ធ្ងរឡើយ ។

នៅក្នុងសុន្ទរកថាស្វាគមន៍និងរបាយការណ៍ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជូន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា៖ ក្រសួងមហាផ្ទៃ បានរៀបចំធ្វើបទបង្ហាញជូនអង្គសន្និបាតនូវសេចក្តីព្រាងរបាយការណ៍ ស្តីពី លទ្ធផលការងារឆ្នាំ២០២១ ទិសដៅការងារឆ្នាំ២០២២ និងផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «**ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព**» របស់រាជរដ្ឋាភិបាលដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ និងបានធ្វើការបែងចែកក្រុមពិភាក្សាផ្តល់ធាតុចូលទៅលើរបាយការណ៍ទិសដៅការងារ ព្រមទាំងប្រធានបទសំខាន់ៗសំដៅលើកកម្ពស់គុណភាពប្រសិទ្ធភាពការងាររបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០២២ និងឆ្នាំខាងមុខទៀត ។

ទន្ទឹមនេះ ផ្អែកតាមការពិភាក្សាអង្គប្រជុំទាំងមូលបានធ្វើការវាយតម្លៃខ្ពស់ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិត និងប៉ិនប្រសព្វរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានដឹកនាំប្រទេសជាតិបន្តរក្សាការពារបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យ បូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ទន្ទឹមការដាក់ចេញនូវគោលការណ៍ វិធានការណ៍នានា បានទាន់ពេលវេលានិងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងឆ្លើយតបចំពោះជំងឺឆ្លងរាតត្បាតជាសកល កូវីដ-១៩ ដើម្បីសង្គ្រោះការពារអាយុជីវិតប្រជាជន និងពុះពារ ជម្នះ ដោះស្រាយបញ្ហាប្រឈមនានា បណ្តាលមកពីវិបត្តិនៃជំងឺនេះ ទប់ល់នឹងសេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយបានបើកប្រទេសឱ្យដំណើរការពេញលេញលើគ្រប់វិស័យ និងការរស់នៅជាមួយជំងឺកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មី ដើម្បីបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យមានការរីកចម្រើនទៅមុខបន្តទៀត ។

ជារួមអង្គសន្និបាតបានធ្វើការវាយតម្លៃអំពីសភាពការណ៍តំបន់ និងសកល ហើយបានកត់សម្គាល់ថា ក្នុងឆ្នាំ២០២២ នេះសភាពការណ៍នយោបាយ និងសន្តិសុខ






☞ ៥៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្តេចក្រឡាហោម អញ្ជើញជាអធិបតី

## « មណ្ឌលកីឡា





សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុង ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវ " មណ្ឌលកីឡាហែលទឹកបាត់ដំបង " ស្ថិតនៅក្នុងសាកលវិទ្យាល័យជាតិបាត់ដំបង សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីរសៀលថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ កន្លងមកនេះ ។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាប្រធានសហព័ន្ធខ្មែរកីឡាហែលទឹក បានមានប្រសាសន៍បញ្ជាក់ថា: វត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** នាពេលនេះមានសារសំខាន់បំផុតក្នុងការចូលរួមចំណែកលើកស្ទួយ



៣គារពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ដំខួនខ្ពស់ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ ហែលទឹក ចាក់ដំបង »



ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាប្រធានសហព័ន្ធខ្មែរកីឡាហែលទឹក

និងអភិវឌ្ឍវិស័យកីឡានៅកម្ពុជា ដើម្បីឈានទៅរកការប្រកួតក្នុងឆាកអន្តរជាតិ (ស៊ីហ្គេម)២០២៣ខាងមុខ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងដើម្បីស្តារកេរ្តិ៍ឈ្មោះកីឡាហែលទឹកកម្ពុជាឡើងវិញ ។

**ឯកឧត្តម ទេសរដ្ឋមន្ត្រី** បានមានប្រសាសន៍បញ្ជាក់ឱ្យដឹងថា៖ មណ្ឌលកីឡាហែលទឹកនេះ សាងសង់លើផ្ទៃដីទំហំ ១១២ម៉ែត្រ គុណនឹង ៦៥ម៉ែត្រ ក្នុងនោះរួមមាន៖ អាងទឹកសម្រាប់ប្រកួត អាងលោតទឹក អាងហែលកំដៅសាច់ដុំ ប៉មលោតទឹក និងអាងទឹកក្នុងដីសម្រាប់រក្សាគុណភាពទឹកអាងទាំងបី ទំហំ ១០ម៉ែត្រ ។ មណ្ឌលកីឡាហែលទឹកនេះរួមមានកន្លែងអង្គុយទស្សនា បន្ទប់ម៉ាស៊ីនចម្រោះ បន្ទប់ឃ្លាំង បន្ទប់ផ្លាស់សម្លៀកបំពាក់ បន្ទប់ទឹកកីឡាករ កីឡាការិនី បន្ទប់ទឹកសាធារណៈ ទីធ្លាចំណតរថយន្ត និងទោចក្រយានយន្ត អគារពហុបំណង បន្ទប់ពិសេសសម្រាប់គណៈអធិបតី បន្ទប់បញ្ជាការប្រកួត បន្ទប់សង្គ្រោះបន្ទាន់ បន្ទប់អាផ្នាកណ្តាល កន្លែងសម្រាករយៈពេលខ្លី បន្ទប់ស្នាក់នៅសម្រាប់កីឡាករទាំងពីរភេទ បន្ទប់បរិភោគ និងចង្ក្រានចំអិនអាហារផងដែរដោយចំណាយថវិកាសរុបជាង ៧លានដុល្លារសហរដ្ឋអាមេរិក។

០៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា











តមកពីទំព័រ ០៨

**សម្ដេចក្រឡាហោម អញ្ជើញជាអធិបតី ...**

បានប្រសាសន៍សំណេះសំណាល ក្នុងពិធីនោះ **សម្ដេចក្រឡាហោម** បានសម្ដែងនូវក្ដីសោមនស្សរីករាយ ពោរពេញដោយមោទនភាព ដែលបាន អញ្ជើញជាអធិបតីក្នុង ពិធី សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ " មណ្ឌលកីឡាហែលទឹកបាត់ដំបង "ក៏ដូចជាការចូលរួមអបអរសាទរចំពោះកីឡាករ កីឡាការិនី ដែលទទួលជ័យលាភីក្នុងការប្រកួតបញ្ចេញសមត្ថភាពដ៏ប៉ិនប្រសព្វនៅក្នុងពិធីសម្ពោធពេលនេះ ។

**សម្ដេចក្រឡាហោម** បានប្រសាសន៍បញ្ជាក់ថា៖ " មណ្ឌលកីឡា



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល











ហែលទឹកបាត់ដំបង " គឺជាសមិទ្ធិផលថ្មីសន្លាងមួយរបស់ប្រជាប់ខេត្តបាត់ដំបង ដែលត្រូវបានសាងសង់ឡើង ដើម្បីលើកកម្ពស់ឱ្យយុវជន កីឡាករ កីឡាការិនី ហ្វឹកហាត់ពង្រឹងសមត្ថភាពជំនាញកីឡាហែលទឹកសំរាប់ត្រៀមឈានទៅចូលរួមក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ ដណ្តើមមេដាយ និងបង្ហាញឱ្យប្រទេសនានានៅលើសកលលោកស្គាល់ពីកម្ពុជា ឱ្យកាន់តែច្បាស់ ។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានអំពាវនាវឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការថែរក្សាទ្រព្យសម្បត្តិទាំងនេះទុកប្រើប្រាស់អោយបានយូរអង្វែងសំរាប់ជាកេរ្តិ៍មរតកកូនចៅយើងជំនាន់ក្រោយៗទៀត ៕



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# សេចក្តីប្រកាសព័ត៌មាន អំពីលទ្ធផល
# លើកទី ៣ ស្តីពីកិច្ចសហប្រតិបត្តិការ







ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម លើកទី៣ ស្តីពី កិច្ចសហប្រតិបត្តិការបង្ការនិងបង្ក្រាបបទល្មើស រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នារសៀលថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូសន្និសីទពីចម្ងាយ ។

សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមនាយឧត្តមសេនីយ៍ **វិល័យ ឡាខាំហ្វង** រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណឡាវ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **តូ ឡឹម** សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កម្ពុជា– ឡាវ– វៀតណាម បង្ការ និងបង្ក្រាបបទល្មើស





បានសម្តែងការអបអរសាទរចំពោះទំនាក់ទំនងដ៏ល្អរវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងបី ក្នុងស្មារតីមិត្តភាពជាប្រពៃណី សាមគ្គីភាព និងភាពជាអ្នកជិតខាងល្អ ដែលតាមរយៈទំនាក់ទំនងនេះ បានរួមចំណែកក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខរវាងប្រទេសទាំងបី កាន់តែសកម្ម និងស៊ីជម្រៅថែមទៀត ។

លើសពីនេះ ថ្នាក់ដឹកនាំនៃក្រសួងទាំងបី ក៏បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងអនុវត្តច្បាប់ និងអាជ្ញាធរពាក់ព័ន្ធនៃភាគីទាំងបី ដែលទោះបីទទួលរងការរំខានដោយវិបត្តិនៃជំងឺកូវីដ-១៩ យ៉ាងណាក្តី ក៏នៅតែបន្តរក្សានូវទំនាក់ទំនង និងកិច្ចសហការជិតស្និទ្ធក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមបានល្អប្រសើរ ជាពិសេស ការដោះស្រាយបាតុភាពផ្សេងៗតាមព្រំដែនដោយឈរលើស្មារតីមិត្តភាព សាមគ្គីភាព និងការគោរពអធិបតេយ្យគ្នាទៅវិញទៅមក ព្រមទាំងកិច្ចសហប្រតិ

☞ ៣៩



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:06 AM

# សម្តេចក្រឡាហោម៖ អោយតែមាន





កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យក្រុមនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលី ចំនួន ២៧រូប ចូលជួបសំដែងការគួរសមនៅទីស្តីការក្រសួងមហាផ្ទៃ ។

នៅក្នុងជំនួបសំដែងការគួរសមនោះ តំណាងនិស្សិតអាហារូបករណ៍ បានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឲ្យក្រុមនិស្សិតអាហារូបករណ៍ទាំងអស់ បានចូលជួបសំដែងការគួរសមនិងទទួលអនុសាសន៍ណែនាំមុនពេលចាកចេញទៅបន្តការសិក្សានៅប្រទេសអូស្ត្រាលី ។

អញ្ជើញផ្តល់អនុសាសន៍ នាឱកាសនោះ **សម្តេចក្រឡាហោម** បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅ និងអបអរសាទរចំពោះនិស្សិតជ័យលាភីអាហារូបករណ៍ទាំងអស់ ដែលបានតស៊ូសិក្សារៀនសូត្រក្នុងរយៈពេលកន្លងមករហូតទទួលបានអាហារូបករណ៍ទៅសិក្សាបន្តនៅប្រទេសអូស្ត្រាលី ។

ជាមួយគ្នានោះដែរ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍សំដែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់និស្សិតជ័យលាភីទាំងអស់ បើទោះបីជាជាប់រវល់ការងារប្រចាំថ្ងៃ

☞ ៣៧



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/

# ការតស៊ូព្យាយាម ជោគជ័យប្រាកដជាមាន»













៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:06 AM
https://online.fliphtml5.com/vhqfg/sjtw/ Page 17 of 68

# សម្តេចក្រឡាហោម គាំទ្រគំនិតផ្តួចផ្តើម របស់ប្រធានសមាគម ជប៉ុន-កម្ពុជា



នារសៀលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យ ឯកឧត្តម **តាកាហាស៊ី ហ្វូមៃគី** ប្រធានសមាគមជប៉ុន-កម្ពុជា (JCA) និងជាអតីត ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

ឯកឧត្តម **តាកាហាស៊ី ហ្វូមៃគី** ប្រធានសមាគមជប៉ុន-កម្ពុជា (JCA) បានជម្រាបជូន **សម្តេចក្រឡាហោម** ពីគោលបំណងរបស់ ឯកឧត្តម ក្នុងការធ្វើដំណើរទស្សនកិច្ចមកប្រទេសកម្ពុជានាពេលនេះ ថ្រាបថា៖ **គោលបំណងទី១** គឺការរៀបរៀបចំដំណើរទស្សនកិច្ច នៅឆ្នាំក្រោយរបស់ប្រតិភូធុរកិច្ចជប៉ុន ដែលរួមមានក្រុមហ៊ុនSMEជប៉ុនជាច្រើន **ទី២**-ការអនុវត្តគម្រោងដែលហៅ ថាសូត្រមាសរបស់កម្ពុជា(Cambodia Golden Silk) ដែលគម្រោងនេះនឹងជួយលើកកម្ពស់សិប្បកម្មសូត្រនៅកម្ពុជា ។

**ឯកឧត្តម** ប្រធានសមាគមបានបញ្ជាក់ បន្តទៀតថា៖ សម្រាប់ដំណើរទស្សនកិច្ចរបស់ក្រុមហ៊ុនSMEជប៉ុនមកកាន់កម្ពុជា នៅឆ្នាំក្រោយនោះ គឺក្រុមហ៊ុនទាំងនោះធ្លាប់បានធ្វើដំណើរទស្សនកិច្ចមកកាន់កម្ពុជាម្តងរួចមកហើយ កាលពីខែធ្នូ ឆ្នាំ២០១៩ ក្នុងនោះប្រតិភូធុរកិច្ចក៏បានចូលជួបសម្តែងការគួរសមជាមួយ **សម្តេចក្រឡាហោម** ផងដែរ ក្នុងជំនួបនាឱកាសនោះក្រុមអ្នកវិនិយោគបានទទួលអនុសាសន៍ណែនាំផ្សេងជាច្រើនពាក់ព័ន្ធនឹងការវិនិយោគនៅកម្ពុជា ។ ប៉ុន្តែដោយសារតែ ការរីករាលដាលនៃជំងឺកូវីដ១៩ ទើបប្រតិភូធុរកិច្ចSMEរបស់ជប៉ុនធ្វើការពន្យាពេលមកទស្សនកិច្ចនៅកម្ពុជារហូតដល់បច្ចុប្បន្ន ប៉ុន្តែពេលនេះស្ថានភាពជំងឺកូវីដ១៩ ជប៉ុន-កម្ពុជា មានភាពធូរស្រាល ទើប **ឯកឧត្តម** រៀបរៀបចំដំណើរទស្សនកិច្ចលើកទី២សាជាថ្មីនៅឆ្នាំក្រោយ ។

**ឯកឧត្តម** ប្រធានសមាគមបានបន្តថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សមាគមជប៉ុន-កម្ពុជា (JCA) បានជំរុញ និងទាក់ទាញក្រុមហ៊ុនSMEជាច្រើនឱ្យក្លាយជាសមាជិកក្នុងនោះសមាគមក៏បានទាក់ទាញឱ្យក្រុមអ្នកវិនិយោគទាំងនោះ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







មកធ្វើការវិនិយោគនៅកម្ពុជា ។ ជាមួយគ្នានេះដែរ **ឯកឧត្តម** បានសម្តែងនូវការរីករាយ និងសង្ឃឹមជឿជាក់ថា ក្នុងឱកាសនៃដំណើរទស្សនកិច្ចជាលើកទី២របស់ប្រតិភូធុរកិច្ចSMEរបស់ជប៉ុននៅឆ្នាំក្រោយ **សម្តេចក្រឡាហោម** និងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ទទួលជួបប្រតិភូធុរកិច្ច ដើម្បីអាចទទួលបាននូវបទពិសោធន៍ និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ក្នុងការវិនិយោគនៅកម្ពុជា ពីសំណាក់ **សម្តេចក្រឡាហោម** ផងដែរ ។

លើសពីនេះទៀត **ឯកឧត្តម** ក៏បានលើកឡើង ពីមូលនិធិមួយរបស់កម្ពុជា ដែលមានឈ្មោះថាមូលនិធិ « **សម្តេចតេជោអភិវឌ្ឍសហគ្រាសធនតូច និងមធ្យម**» ដែលមានសម្តេចក្រឡាហោម ជាប្រធានកិត្តិយស ហើយមូលនិធិនេះបង្កើតឡើង ដើម្បីប្រមូលទុននិងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋធ្វើការនៅក្នុងវិស័យ SMEដើម្បីលើកកម្ពស់SMEនៅកម្ពុជា ។

មានប្រសាសន៍ឆ្លើយតបវិញ **សម្តេចក្រឡាហោម** បានសម្តែងនូវការគាំទ្រចំពោះគំនិតផ្តួចផ្តើមរបស់ ឯកឧត្តម ប្រធានសមាគមជប៉ុន-កម្ពុជា ដោយ **សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា: SME នេះពិតជាមានសារៈសំខាន់ចំពោះសេដ្ឋកិច្ច ។ ព្រមជាមួយនោះ **សម្តេចក្រឡាហោម** ក៏បានស្នើដល់ ឯកឧត្តម Takahashi Fumiaki ឱ្យពិនិត្យលទ្ធភាពសហការជាមួយ **មូលនិធិសម្តេចតេជោអភិវឌ្ឍសហគ្រាសធនតូច និងមធ្យម** ដើម្បីលើកកម្ពស់ការទំនាក់ទំនងរួមគ្នា៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឯកឧត្តម សក់ សេដ្ឋា អញ្ជើញពិនិត្យ អាគារទីស្តីការថ្មី













ព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មការសាងសង់**អាគារទីស្តីការថ្មី** របស់ក្រសួងមហាផ្ទៃ រួមដំណើរ ដោយឯកឧត្តម ជាអនុប្រធាន អនុប្រធានអចិន្ត្រៃយ៍ ព្រមទាំង ឯកឧត្តម ជាសមាជិកគណៈកម្មការសាងសង់ និងសហការី ជាច្រើនរូបទៀតបាន អញ្ជើញចុះត្រួតពិនិត្យវឌ្ឍនភាពការងារនៃដំណើរការសាងសង់ **អាគារទីស្តីការថ្មី** របស់ក្រសួងមហាផ្ទៃ ។



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# វឌ្ឍនភាពនៃសកម្មភាពសាងសង់ របស់ក្រសួងមហាផ្ទៃ



គួររំលឹកដែរថា ៖ **អាគារទីស្តីការថ្មី** របស់ក្រសួងមហាផ្ទៃ បានបើកការដ្ឋានសាងសង់កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវត្រីស័ក ពស ២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**លោកជំទាវ** ដែលគិតមកដល់ពេលនេះមានរយៈពេលជិត៣ខែ ។ តាមការ

៣៦











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# កិច្ចប្រជុំដកពិសោធន៍ការងារគ្រប់គ្រងវត្ថុមាន

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំដកពិសោធន៍ការងារគ្រប់គ្រងវត្ថុមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា នៅ








៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
អគ្គស្នងការនគរបាលជាតិ



ឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ
អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

សាលប្រជុំអគ្គនាយកដ្ឋានអន្តោប្រវេសន៍។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានបញ្ជាក់ថា ៖ ចំពោះប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា (FPCS) មានការពាក់ព័ន្ធចំនួន ២ចំណុច ៖ **ទី១** គឺការអប់រំ និងផ្សព្វផ្សាយបន្តទៀតចំពោះម្ចាស់ គោលដៅគិត ទាំងអាជីវកម្ម និងការស្នាក់នៅរបស់ជនបរទេស ដែលត្រូវគៀងគរអោយអ្នកទាំងអស់នោះចូលរួម ដើម្បីអនុវត្តជាពិសេសគឺការស្ម័គ្រចិត្តបំពេញក្នុងលក្ខខណ្ឌរបស់មន្ត្រីយើង។

# ជនបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជា






**ទី២** នៅលើសមត្ថកិច្ច ដែលកិច្ចការនេះជាកិច្ចការរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលមានមន្ត្រីជំនាញឯកទេសគឺស្នងការរងទទួលបន្ទុកអន្តោប្រវេសន៍មាននាយការិយាល័យនិងអធិការរងគ្រប់គ្រងជនបរទេសនៅខណ្ឌ-ស្រុក-ក្រុង អនុវត្ត ។ ហើយការងារនេះស្នងការដ្ឋាននគរបាលរាជធានី-ខេត្តទាំង២៥ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីពេលនេះទៅ ដើម្បីអោយនាយរងប៉ុស្តិ៍បានទទួលភារកិច្ចនេះទាំងការបង្រៀនបច្ចេកទេស ដឹងពីរបៀប និងប្រមូលផ្តុំគ្នាដើម្បីធ្វើការងារនេះដែលមានអ្នកទទួលបន្ទុកច្បាស់លាស់ ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានមានប្រសាសន៍ទៀតថា ៖ បទពិសោធន៍ក្នុងការគ្រប់គ្រងកិច្ចការសន្តិសុខសណ្តាប់

៤០



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# អនុស្សរណៈ និងកិច្ចព្រមព្រៀង ចំនួន ២ ត្រូវបាន គ ជ ប ជ ចុះហត្ថលេខាជាមួយការីតាសស្វីស និងអង្គការតំណាក់ទឹក











៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល









កាលពីព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ ២០២២ នៅអគ្គលេខាធិការដ្ឋាន គ ជ ប ជ បានរៀបចំ ពិធី ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ ជ ប ជ និងអង្គការការីតាសស្វីស ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ឆ្នាំ២០២២-២០២៤ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ ប ជ ដោយមានការអញ្ជើញចូលរួមពីសំណាក់ លោក **ម៉ាក ភ្លូកល័រ** នាយកប្រចាំប្រទេសរបស់អង្គការ **ការីតាសស្វីស** ព្រមទាំង លោកវេជ្ជបណ្ឌិត **សំ សុវណ្ណារិទ្ធ** នាយកប្រតិបត្តិអង្គការ **តំណក់ទឹក** នៅកម្ពុជា និងសហការី ។

លោកជំទាវ រដ្ឋលេខាធិការ បានអញ្ជើញមានប្រសាសន៍បញ្ជាក់ថា ៖ អនុស្សារណៈ និងកិច្ចព្រមព្រៀងដែលត្រូវចុះហត្ថលេខានៅពេលនេះមានចំនួនពីរគឺ **ទី១**អនុស្សារណៈយោគយល់គ្នានៅក្នុងការធ្វើកិច្ចសហការគ្នារវាងការីតាសស្វីស គ ជ ប ជ ជាមួយអង្គការ **តំណក់ទឹក** និង**ទី២** គឺជាផែនទីប្រតិបត្តិការមួយដែលយើងហៅថា កិច្ចព្រមព្រៀងធ្វើការជាមួយគ្នាក្នុងរយៈពេល៣ឆ្នាំ ដោយផ្តោតជាសំខាន់ទៅលើការបង្ការទប់ស្កាត់ កិច្ចការពារ និងការធ្វើសមាហរណកម្មដល់ជនរងគ្រោះដែលត្រូវជួញដូរមនុស្ស ពិសេសធ្វើទៅលើពលករដែលឆ្លងកាត់ព្រំដែនទៅធ្វើការនៅក្រៅប្រទេសដោយសុវត្ថិភាព ហើយយើងក៏មានមណ្ឌល

៣៨



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពី គោរមងារ ឧកញ៉ា

## ត្រូវបានក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សា



ព្រឹកថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ កន្លងមកនេះ ក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពី **គោរមងារ ឧកញ៉ា** តាមប្រព័ន្ធវីដេអូ Zoom ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារអន្តរក្រសួង ដោយមានការអញ្ជើញចូលរួមពីសំណាក់អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួងជាច្រើនរូបដែលជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផងដែរ ដើម្បីសិក្សារៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការ**គ្រប់គ្រង ឧកញ៉ា ការផ្ដល់គោរមងារ ឧកញ៉ា និងការដកហូតគោរមងារ ឧកញ៉ា**។

ឯកឧត្តម រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារអន្តរក្រសួង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ និងសមាជិកក្រុមការងារទាំងអស់ដែលបានចូលរួមក្នុងអង្គប្រជុំនេះ និងជាពិសេសបានផ្ដល់ធាតុចូលយ៉ាងល្អៗដើម្បីកែសម្រួលទៅលើខ្លឹម



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





សារនៃសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី **គោរមងារឧកញ៉ា**ឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។

សូមជម្រាបជូនថា៖ ក្រុមការងារអន្តរក្រសួងដែលមានភារកិច្ចពិនិត្យ ពិភាក្សានិងកែសម្រួលខ្លឹមសារសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី **គោរមងារឧកញ៉ា** ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ដើម្បីសិក្សាស្រាវជ្រាវ ផ្តួចផ្តើមក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា ការដកហូតគោរមងារឧកញ៉ា និងសិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីជាធាតុចូលសម្រាប់រៀបចំការគ្រប់គ្រងឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា ដែលមានសមាសភាពចំនួន ១៧រូប ។ ក្នុងនោះមាន ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន និងអនុប្រធានចំនួន ១រូប ព្រមទាំងសមាជិកសមាជិកាចំនួន ១០រូប ដែលជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

ក្រុមការងារនេះ ត្រូវសិក្សាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ឧកញ៉ាក្នុងការចូលរួមកិច្ចការសង្គម ធ្វើការពិគ្រោះយោបល់ជាមួយបណ្តាក្រសួង- ស្ថាប័ន អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មាន បម្រើឱ្យការរៀបចំបែបបទ និងនីតិវិធីនៃការគ្រប់គ្រងឧកញ៉ា ការស្នើសុំផ្តល់គោរមងារឧកញ៉ា អ្នកឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា ។

ជាមួយគ្នានេះដែរ ក្រុមការងារនេះត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារសម្រាប់គោរពជូន សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និងផ្តល់យោបល់ដឹកនាំរៀបចំឯកសារពាក់ព័ន្ធជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច ព្រមទាំងបំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# ប្រគល់រថយន្ត Pick Up ២០២២ ចំនួន ១៩គ្រឿង ដែលមិនទាន់បាន



នាព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់រថយន្តជូនវរសេនាតូចនគរបាលការពារព្រំដែនប្រចាំទិសភូមិភាគទី១ ភូមិភាគទី២ និងភូមិភាគទី៣ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

នៅក្នុងរបាយការណ៍ស្វាគមន៍របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ បានបញ្ជាក់ឱ្យដឹងថា៖ គិតចាប់ពីឆ្នាំ២០១៩មក **សម្តេចក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានផ្តល់អំណោយដ៏ថ្លៃថ្លានូវរថយន្ត Pick-Up ចំនួន ៥លើករួចមក ហើយដែលមានចំនួនសរុប ២៤៥គ្រឿង ជូនដល់អង្គ



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ជូនអង្គភាព និង ស្នងការដ្ឋាននគរបាលខេត្ត ទទួលរថយន្ត

ភាពចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ ។ ហើយនៅពេលនេះ **សម្តេច** បានផ្តល់រថយន្តម៉ាក Ford Ranger Pick Up XLT 3.2L ផលិតឆ្នាំ ២០២២ ចំនួន ១៩គ្រឿងបន្ថែមទៀត ជូនវរសេនាតូចនគរបាលការពារព្រំដែនចំណុះភូមិភាគ ១,២និងភូមិភាគ៣ ដែលក្នុងនោះគ្រោងផ្តល់ជូននាយកដ្ឋាននគរបាលព្រំដែនទឹកចំនួន ៣គ្រឿង ស្នងការដ្ឋាននគរបាលខេត្តកណ្តាលទទួលបាន ១គ្រឿង កំពត ១គ្រឿង កោះកុង ២គ្រឿង រតនគិរី ២គ្រឿង ស្វាយរៀង ២គ្រឿង ក្រចេះ ១គ្រឿង មណ្ឌលគិរី ២គ្រឿង ព្រៃវែង ១គ្រឿង ស្ទឹងត្រែង ១គ្រឿង ត្បូងឃ្មុំ ២គ្រឿង

☞ ៣៥



ឯកឧត្តម នាយឧត្តមសេនីយ៍ សេង យូអ៊ាន់ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ប្រកាសចូលកាន់មុខតំណែង នាយក-នាយករងសាលា និងប្រធាននាយកដ្ឋាន នៃ*សាលាជាតិរដ្ឋបាលមូលដ្ឋាន*




សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសចូលកាន់មុខតំណែងនាយក នាយករងសាលា និងប្រធាននាយកដ្ឋាន នៃ**សាលាជាតិរដ្ឋបាលមូលដ្ឋាន** ប្រារព្ធនៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ។

ឯកឧត្តម **ប្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានអញ្ជើញធ្វើរបាយការណ៍ស្វាគមន៍ដោយបញ្ជាក់ថា៖ សាលាជាតិរដ្ឋបាលមូលដ្ឋាន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា សម្រេចតម្លើងឋានៈឱ្យស្មើអគ្គនាយកដ្ឋានកាលពីឆ្នាំ២០២១ ដោយមាននាយកដ្ឋាន ៤ ជាចំណុះ រួមមាន **នាយកដ្ឋានកិច្ចការទូទៅ នាយកដ្ឋានផែនការ និងកិច្ចសហប្រតិបត្តិការ** នាយក







៣កាពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:06 AM








ឯកឧត្តម ប្រាក់ សំអឿន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

***ដ្ឋានស្រាវជ្រាវ និងផ្សព្វផ្សាយ និងនាយកដ្ឋានបណ្តុះបណ្តាល*** ។

*អញ្ជើញបានប្រសាសន៍នាឱកាសនោះ* **សម្តេចក្រឡាហោម** *បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលបានខិតខំបំពេញក្នុងនាទីយ៉ាងសកម្មនៅឆ្នាំក្នុង២០២១ ប្រកបដោយការទទួលខុសត្រូវ ស្មារតីម្ចាស់ការ និងរួមគ្នាពុះពារសម្រេចបានសមិទ្ធផលនានាគួរឱ្យកត់សម្គាល់ ទោះប្រឈមនឹងជំងឺកូវីដ-១៩យ៉ាងណាក្តី* ។

**សម្តេចក្រឡាហោម** *បានមានប្រសាសន៍បញ្ជាក់ទៀតថា៖ ជាមួយសមិទ្ធផលដ៏ថ្លៃថ្លាដែលសម្រេចបានជាបន្តបន្ទាប់មកនេះ នៅថ្ងៃនេះក៏ជារបត់ថ្មីមួយទៀតសម្រាប់ក្រសួងមហាផ្ទៃ ដែលបង្កើតអង្គភាពថ្មីមួយ មានថ្នាក់ស្មើអគ្គនាយកដ្ឋាន គឺសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីទទួលខុសត្រូវការរៀបចំការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព* ។

**សម្តេចក្រឡាហោម** *បានប្រសាសន៍សង្កត់ធ្ងន់ថា៖ ថាការបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាននេះ មិនមែនជារឿងចៃដន្យ*

☞ ៤២



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/sjtw/




# កិច្ចប្រជុំបូកសរុបលទ្ធផលការងារ
## និង លើកទិសដៅការងារ

នាព្រឹកថ្ងៃអង្គារ ទី០៩ ខែកុម្ភៈ ឆ្នាំ ២០២២ នេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក(គ.ស.ច.គ) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ ២០២១ និង លើកទិសដៅការងារឆ្នាំ២០២២ របស់ គ.ស.ច.គ ។



ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន



នៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ២០២១ ដែលអានដោយឯកឧត្តម នាយឧត្តមសេនីយ៍ **យុន ឈុនី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ស.ច.គ បានបញ្ជាក់ថា៖ កិច្ចប្រតិបត្តិការត្រួតពិនិត្យអនុវត្តច្បាប់ចរា



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# សុវត្ថិភាពចរាចរណ៍ផ្លូវគោក ប្រចាំឆ្នាំ ២០២១ ឆ្នាំ ២០២២ របស់ គ.ស.ច.គ





ចរណ៍ផ្លូវគោកតាមអនុក្រឹត្យលេខ៣៩ អនក្រ.បក.ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ប្រចាំឆ្នាំ២០២១ ទទួលលទ្ធផលដូចជា៖ ត្រួតពិនិត្យយានយន្តសរុបចំនួន ២.១១២.៦៧០គ្រឿង ក្នុងនោះ ម៉ូតូចំនួន ៦៤%។ រកឃើញយានយន្តល្មើស និងពិន័យចំនួន ២២៣.៨៧៩គ្រឿង (២២៤.៥២២ករណី) ស្មើ១១% ក្នុងនោះម៉ូតូចំនួន ១៦៨.៩៥៦គ្រឿង (១៦៨.៩៥៧ករណី) ស្មើ៧៥% និងរថយន្តចំនួន ៥៤.៩២៣គ្រឿង (៥៥.៥៦៥ករណី) និងធ្វើការពិន័យចំពោះបទល្មើសចរាចរណ៍ឆ្នាំ ២០២១ បានចំនួន ១៩.៩១១.៨៩៥.០០០រៀល។

ទន្ទឹមនេះគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឆ្នាំ២០២១ បានកើតឡើង ចំនួន ២.៦៧០លើក បណ្តាលឱ្យស្លាប់ចំនួន

៦៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:06 AM

# សម្តេចក្រឡាហោម អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតថ្មី ហ្វីលីពីន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



នារសៀលថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យលោកជំទាវ **ម៉ារៀ អាមីលីតា ស៊ីឃ្វីណូ** (Maria Amelita C.Aquino) ឯកអគ្គរដ្ឋទូតថ្មីហ្វីលីពីន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

នៅក្នុងជំនួបពិភាក្សានោះ **សម្តេចក្រឡាហោម** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន **លោកជំទាវ** ឯកអគ្គរដ្ឋទូតដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋហ្វីលីពីនប្រចាំនៅកម្ពុជា ដោយ **សម្តេច** មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអាណត្តិការទូតរបស់ **លោកជំទាវ** កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងកម្ពុជា និងហ្វីលីពីន នឹងកាន់តែបន្តរីកចម្រើនថែមទៀត រួមទាំងកិច្ចសហប្រតិបត្តិការក្របខណ្ឌគ្រួសារអាស៊ានផងដែរ ។ ជាពិសេសដោយនៅក្នុងឆ្នាំ២០២២ ព្រះរាជាណាចក្រកម្ពុជាទទួលធ្វើជាប្រធានអាស៊ាន **សម្តេចក្រឡាហោម** ក៏សង្ឃឹមថាប្រទេសហ្វីលីពីននឹងបន្តចូលរួមគាំទ្រដល់ការបំពេញតួនាទីនេះរបស់កម្ពុជា ដើម្បីបម្រើផលប្រយោជន៍រួមរបស់អាស៊ានទាំងមូល ក៏ដូចជារួមចំណែកដល់ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងហ្វីលីពីនឲ្យកាន់តែខ្លាំងក្លាថែមទៀត ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើវិស័យដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ រួមមាន**ទីមួយ** គឺវិស័យសន្តិសុខ និង**ទីពីរ**គឺ ពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ **សម្តេចក្រឡាហោម** បានសម្តែងក្តីសង្ឃឹមថាភាគីទាំងពីរនឹងបន្តពង្រីកកិច្ចសហប្រតិបត្តិការនេះឲ្យកាន់តែទូលំទូលាយថែមទៀត ជាពិសេសទៅលើការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការចែករំលែកបទពិសោធន៍ទៅវិញទៅមកពាក់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/







ព័ន្ធទៅនឹងការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានជម្រាបជូន **លោកជំទាវ** ពាក់ព័ន្ធទៅនឹងដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលមកដល់ពេលនេះរាជរដ្ឋាភិបាលកំពុងអនុវត្តផែនការជាតិរយៈពេល១០ឆ្នាំ ដំណាក់កាល**ទី២**របស់ខ្លួន ដែលបានមើលឃើញនូវលទ្ធផលនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជានាពេលកន្លងមក ព្រោះថា: នៅដំណាក់កាល**ទី២**នេះក៏ជាដំណាក់កាលដ៏មានសារៈសំខាន់ក្នុងការផ្ទេរនូវធនធាន និងអំណាចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ។

ជាការឆ្លើយតប លោកជំទាវ **ម៉ារៀ អាមីលីតា ស៊ុយ៉ូណូ** បានជម្រាប **សម្តេចក្រឡាហោម** នូវការចូលរួមសម្តែងការអបអរសាទរចំពោះជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងជំងឺកូវីដ ១៩ និងបានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែកយ៉ាងសកម្មរបស់ក្រសួងមហាផ្ទៃក្នុងការសម្រេចបាននូវជោគជ័យទៅលើការងារគ្រប់គ្រង ក៏ដូចជាយុទ្ធនាការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ១៩ ។

លោកជំទាវឯកអគ្គរដ្ឋទូត ក៏បានជម្រាបជូន **សម្តេចក្រឡាហោម** ទៀតថា ហ្វីលីពីន នៅតែបន្តគាំទ្រកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ជាពិសេសក្នុងឱកាសដែលកម្ពុជាធ្វើជាប្រធានអាស៊ាន ព្រមទាំងបន្តចូលរួមគាំទ្ររាល់ព្រឹត្តិការណ៍ដែលក្រសួងមហាផ្ទៃ ត្រូវធ្វើជាប្រធានដឹកនាំនៅក្រោមក្របខណ្ឌអាស៊ាននេះផងដែរ ។

ក្រៅពីកិច្ចសហប្រតិបត្តិការពហុភាគីក្នុងក្របខណ្ឌអាស៊ាន **លោកជំទាវ** ឯកអគ្គរដ្ឋទូត ក៏បានសម្តែងនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការពង្រីកនូវកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែខ្លាំងឡើងថែមទៀត ជាពិសេសនៅក្នុងវិស័យសន្តិសុខដែលមានកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន បញ្ហាគ្រឿងញៀន បញ្ហាបទល្មើសបច្ចេកវិទ្យា និងអំពើជួញដូរមនុស្សជាដើម ដែលកិច្ចការទាំងនេះមួយផ្នែកធំស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃកម្ពុជា ។

ទន្ទឹមនេះដែរ **លោកជំទាវ** ក៏បានសម្តែងនូវគោលបំណងក្នុងការពង្រីកទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ហ្វីលីពីន ជាមួយកម្ពុជាតាមរយៈការបង្កើតឲ្យមានការផ្លាស់ប្តូរទស្សនកិច្ច និងការចងសម្ព័ន្ធមេត្រីភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសទាំងពីរផងដែរ ៕



**៣កុំ** ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:06 AM



# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន

## ទទួលជួបពិភាក្សាការងារជាមួយអនុព័ន្ធសន្តិសុខផ្ទៃក្នុង អមស្ថានទូតបារាំង ប្រចាំប្រទេសវៀតណាម ទទួលបន្ទុក កម្ពុជា ឡាវ វៀតណាម



កាលពីរសៀលថ្ងៃ ៩ ខែកុម្ភៈ ឆ្នាំ ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតអោយលោកស្រី ណាថាលី កាលីយេ Nathalie Carlier អនុព័ន្ធសន្តិសុខផ្ទៃក្នុង អមស្ថានទូតបារាំងប្រចាំប្រទេសវៀតណាម ទទួលបន្ទុកកម្ពុជា ឡាវ វៀតណាម ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

នៅក្នុងជំនួបដ៏មានសារសំខាន់នេះភាគីបារាំង បានឯកភាពចំពោះលទ្ធផលកិច្ចសហប្រតិបត្តិការរវាងនគរបាលបារាំង និងនគរបាលជាតិកម្ពុជា ដែលធ្លាប់មានកន្លងមកពាក់ព័ន្ធនិងការចូលរួមវគ្គបណ្តុះបណ្តាល និងការផ្លាស់ប្តូរព័ត៌មាន ។ ទន្ទឹមនេះភាគីបារាំងក៏បានជូនព័ត៌មានពាក់ព័ន្ធ និងបណ្តាសិក្ខាសាលាមួយចំនួនដែលគ្រោងនឹងធ្វើនាពេលខាងមុខ ហើយបានស្នើសុំឲ្យភាគីកម្ពុជាចូលរួម ជាពិសេសសិក្ខាសាលាដែលផ្តោតលើបញ្ហាគ្រឿងញៀន ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/







មានប្រសាសន៍ឆ្លើយតបវិញ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានឯកភាព ក្នុងការចាត់បញ្ជូនមន្ត្រីដើម្បីទៅចូលរួម សិក្ខាសាលានៅពេលដែលមានលិខិតអញ្ជើញពីភាគីបារាំង ។ ក្រៅពីនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ក៏បានសំដែងនូវការគាំទ្រចំពោះកិច្ចសហប្រតិបត្តិការ ក្នុងការផ្លាស់ប្តូរព័ត៌មានរវាងភាគីទាំងពីរ (នគរបាលកម្ពុជា-បារាំង) ក្នុងការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែន ហើយក៏បានស្នើសុំឲ្យភាគីបារាំងពិចារណាក្នុងការជួយឧបត្ថម្ភគាំទ្រលើការងារបើកវគ្គបណ្តុះបណ្តាលរយៈពេលវែង-ខ្លី ដើម្បីលើកកម្ពស់សមត្ថភាពកសាងធនធានមនុស្ស ជាពិសេសស្នើសុំឲ្យមានការផ្លាស់ប្តូរព័ត៌មានមួយចំនួនពាក់ព័ន្ធព្រឹត្តិការណ៍សំខាន់ៗសម្រាប់ឆ្នាំ២០២២-២០២៣ ដែលរួមមានកិច្ចប្រជុំអាស៊ានណាប៉ូល កិច្ចប្រជុំកំពូលអាស៊ាន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និងការបោះឆ្នោតសកល ក៏ដូចជាព្រឹត្តការណ៍កីឡាស៊ីហ្គេមឆ្នាំ២០២៣ ដែលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះផងដែរ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា





តមកពីទំព័រ ២៦

**ក្រគល់រថយន្ត Pick Up 2022 ចំនួន...**



និងស្នងការដ្ឋាននគរបាលខេត្តតាកែវ ១គ្រឿង សរុបរំលោយរង្វាន់ថ្លៃថ្លារបស់ **សម្តេចក្រឡាហោម** ទាំង ៦លើក មានចំនួន ២៦៤គ្រឿង ក្នុងនោះម៉ាក Mazda Pick Up ៣៣គ្រឿង និង ម៉ាក Ford Ranger Pick Up ២៣១គ្រឿង ។

អញ្ជើញមានប្រសាសន៍ក្នុងឱកាសនោះ **សម្តេចក្រឡាហោម** បានមានប្រសាសន៍កោតសរសើរចំពោះ ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ ដែលបានដឹកនាំការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរនារយៈពេលកន្លងមកដែលបានបង្កលក្ខណៈធ្វើឱ្យប្រជាពលរដ្ឋមានទំនុកចិត្ត និង រស់នៅប្រកបដោយសេចក្តីសុខ ។

ជាមួយនិងការបង្ហាញនូវក្តីសង្ឃឹមចំពោះថ្នាក់ដឹកនាំ និងកងកម្លាំងនគរបាលជាតិទាំងមូលបន្តការចូលរួមគាំទ្រក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ **សម្តេចក្រឡាហោម** ក៏បានផ្តល់ប្រសាសន៍ណែនាំឱ្យកងកម្លាំងនគរបាលទាំងអស់ត្រូវត្រៀមលក្ខណៈចូលរួមគាំទ្រដល់ដំណើរការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពិសេសការបង្កលក្ខណៈឱ្យគ្រប់គណបក្សនយោបាយដែលបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយអាចធ្វើសកម្មភាពស្របទៅតាមច្បាប់ និងដោយគ្មានការរំខាន ។ ទន្ទឹមនេះក៏ត្រូវត្រៀមលក្ខណៈសម្រាប់ការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងឱកាសដែលនៅឆ្នាំ ២០២២ នេះកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអាស៊ាន ព្រមទាំងបន្តត្រៀមលក្ខណៈសម្រាប់ព្រឹត្តិការណ៍បោះឆ្នោត និង ព្រឹត្តិការណ៍កីឡាឆ្នាំ ២០២៣ បន្តទៀត ។

ដោយឡែកពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀនវិញ **សម្តេចក្រឡាហោម** បានមានប្រសាសន៍សង្កត់ធ្ងន់ថា ៖ សព្វថ្ងៃនេះគ្រឿងញៀនកំពុងវាយលុកសង្គមកម្ពុជាដែលទាមទារឱ្យមានការស្វែងរកមូលហេតុនៃបញ្ហានេះ ។ ជាក់ស្តែងការរកឃើញជាបឋមគឺបញ្ហាគ្រឿងញៀនឆ្លងកាត់តាមព្រំដែនចូលមកកម្ពុជា និងការនាំចូលគ្រឿងញៀនសំយោគដែលបញ្ហាគ្រឿងញៀនសំយោគនេះជាបញ្ហាដ៏គួរឱ្យព្រួយបារម្ភបំផុតសម្រាប់កម្ពុជា និងទាមទារអោយសមត្ថកិច្ចពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ឱ្យបានខ្ពស់បំផុតគឺគ្រប់ភាគីទាំងអស់ត្រូវសហការផ្តល់ព័ត៌មានឱ្យគ្នាក្នុងការត្រួតពិនិត្យដំណើរការនាំចូលសារធាតុផ្សេងៗដើម្បីតាមដាន និងសិក្សាបន្ថែម ថាតើសារធាតុនោះអាចត្រូវបានប្រើប្រាស់សំយោគជាគ្រឿងញៀនឬយ៉ាងណា?។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍សំដែងនូវការចាប់អារម្មណ៍ផងដែរអំពីស្ថានភាពចរាចរណ៍នៅកម្ពុជាដែលក្នុងរយៈពេលចុងក្រោយនេះស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ហាក់មានការហក់ឡើងវិញដោយសារកំណើននៃការធ្វើដំណើរតាមផ្លូវក្រោយពេលរាជរដ្ឋាភិបាលបានប្រកាសបើកប្រទេសឡើងវិញ ៕



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:06 AM



ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការ ក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មការសាងសង់អាគារទីស្តីការថ្មី របស់ក្រសួងមហាផ្ទៃ

តមកពីទំព័រ ១៨

## ឯកឧត្តម សក់ សេដ្ឋា អញ្ជើញពិនិត្យ...

វាយតម្លៃរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសកម្មភាពសាងសង់បាន រអះ រអាង បញ្ជាក់ថា៖ គិតត្រឹមថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២២នេះក្រុមហ៊ុនទទួលបន្ទុកសាងសង់បានសម្រេចការងារប្រមាណ ១៥ ភាគរយហើយ ។

ទីតាំង **អាគារទីស្តីការថ្មី** របស់ក្រសួងមហាផ្ទៃ ត្រូវបានសាងសង់ឡើងលើទីតាំងចាស់ដែលមានផ្ទៃដីសរុបទំហំ ៥,៧ហិចតា ស្ថិតនៅលើវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលគ្រោងនឹងបញ្ចប់ការសាងសង់ក្នុងរំឡុងខែសីហាឆ្នាំ ២០២៣ ខាងមុខនេះ ៕

















៣កុំ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/sjtw/

Page 39 of 68



តមកពីទំព័រ ១៤

សម្តេចក្រឡាហោម «ឲ្យតែមានការតស៊ូ ...



ជាបុគ្គលិក នៅផ្នែកវិស័យឯកជន និងជាមន្ត្រីរាជការក្តីក៏នៅតែព្យាយាមខិតខំបញ្ចេញសមត្ថភាពរហូតទទួលបានអាហារូបករណ៍ទៅសិក្សាបន្តនៅប្រទេសអូស្ត្រាលី ។ ដូច្នេះការខិតខំទាំងនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីឆន្ទៈដ៏មោះមុតក្នុងការស្វែងរកចំណេះវិជ្ជា ដើម្បីកសាងអនាគតរបស់ខ្លួនផង ក៏ដូចជាបានចូលរួមចំណែកក្នុងការកសាងអនាគតរបស់ប្រទេសជាតិយើងផង ។

ព្រមជាមួយនេះ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍ ដោយសំដែងនូវក្តីសង្ឃឹមជឿជាក់ថា និស្សិតដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលី ទាំងអស់នឹងបន្តកិច្ចខិតខំប្រឹងប្រែងនេះរហូតទទួលបានជោគជ័យក្នុងការសិក្សាព្រមទាំងនាំយកចំណេះដឹងទាំងនេះមកចូលរួមកសាងប្រទេសជាតិវិញ។ **សម្តេចក្រឡាហោម** បានមានប្រសាសន៍ក្នុងន័យលើកទឹកចិត្ត និងផ្តាំផ្ញើដល់និស្សិតជ័យលាភីទាំងអស់ដោយសង្កត់ធ្ងន់ថា: «**ឲ្យតែមានការតស៊ូ ព្យាយាម ជោគជ័យប្រាកដជាមាន**»។

គួរបញ្ជាក់ថា៖ អាហារូបករណ៍ Australia Awards គឺជាអាហារូបករណ៍អន្តរជាតិដ៏មានកិត្យានុភាពមួយដែលត្រូវបានឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងរួមចំណែកដល់តម្រូវការអភិវឌ្ឍន៍រយៈពេលវែងរបស់ប្រទេសដៃគូ ដោយស្របតាមកិច្ចព្រមព្រៀងសកលទ្វេភាគីនិងតំបន់ ។ Australia Awards មានគោលបំណងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ព្រមទាំងចូលរួមចំណែកក្នុងការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រជាជននៃប្រទេសទាំងពីរ ។ លើសពីនេះទៅទៀតក៏បានផ្តល់ឱកាសសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ វិជ្ជាជីវៈដល់ប្រជាជនកម្ពុជាដែលមានទេពកោសល្យ និងមានបំណងនាំយកនូវឥទ្ធិពលវិជ្ជមានមកកាន់ប្រទេសរបស់ខ្លួនវិញក្នុងគោលបំណងកសាងអាជីពការងារដែលរួមចំណែកដល់តម្រូវការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា នាពេលអនាគត ៕



៣គារពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



តមកពីទំព័រ ២២

## អនុស្សរណៈ និងកិច្ចព្រមព្រៀង...

មួយ ហៅថា មណ្ឌលទទួលពលករកំរៀងសម្រាប់ គ ជ ប ជ ដែលគាំទ្រដោយអង្គការ **ការីតាសស្វីស** សម្រាប់ទទួលពលករដែលវិលត្រឡប់ពីក្រៅប្រទេសមកវិញ ដើម្បីធ្វើការចុះបញ្ជី និងមានការផ្តល់ព័ត៌មានពីសេវាផ្សេងៗមួយចំនួនទៀត។

ដោយឡែកពាក់ព័ន្ធ និងអង្គការ **តំណក់ទឹក** វិញ លោកជំទាវ រង្គលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ ប ជ បានមានប្រសាសន៍បញ្ជាក់បន្ថែមថា ៖ អង្គការនេះ ក៏មានមួយមណ្ឌលផងដែរ ដែលមានទីតាំងស្ថិតនៅក្រុងប៉ោយប៉ែត ក្នុងការធ្វើកិច្ចសហការគ្នា ដើម្បីឲ្យលំហូរឆ្លងកាត់ព្រំដែនរបស់ពលករកម្ពុជា នៅតាមបណ្តោយព្រំដែនមានទំនាក់ទំនងពីខេត្តមួយទៅខេត្តមួយទៀត ។ មណ្ឌលទទួលពលករ ឬមណ្ឌលសំចត ដែលកំពុងដំណើរការបច្ចុប្បន្ននេះ ទទួលពលករដែលវិលត្រឡប់ពីក្រៅប្រទេសវិញ ដើម្បីធ្វើការចុះបញ្ជី ឬមួយមានការផ្តល់ព័ត៌មានពីសេវាមួយចំនួនដែលបច្ចុប្បន្នខេត្ត បាត់ដំបងមានមណ្ឌលកំរៀង និងតទៅមុខទៀតយើងមានគម្រោងសាងសង់មណ្ឌលនៅតាមព្រំដែនបន្តទៀត ។ ជាពិសេសនៅថ្ងៃអនាគត លោកជំទាវ សង្ឃឹមថាភាគីពាក់ព័ន្ធទាំងឡាយ ដូចជាអង្គការ **តំណក់ទឹក** និងអង្គការដែលពាក់ព័ន្ធសម្រាប់ផ្តល់សេវាជួយដល់ជនរងគ្រោះអាចធ្វើការជាមួយគ្នាដោយចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃខេត្តពាក់ព័ន្ធពិសេសខេត្តដែលមានសកម្មភាពនៅតាមព្រំដែន ដើម្បីឲ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាពខ្ពស់ និងមានដៃគូរកាន់តែច្រើនចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលយើងចាប់ផ្តើមរួមគ្នាតាំងពីការបង្ការ ទប់ស្កាត់មិនឲ្យមានបទល្មើសរំលោភបំពាន ឬមួយក៏ធ្វើឲ្យខាតបង់ផលប្រយោជន៍របស់ប្រជាជន និងសំខាន់ជាងនេះទៀត គឺរួមគ្នាក្នុងការផ្តល់សេវាសម្រាប់កិច្ចការពារទៅដល់ជនរងគ្រោះយើង និងធ្វើឲ្យការធ្វើសមាហរណកម្មរបស់យើងទៅក្នុងសហគមន៍ទទួលបានជោគជ័យ និងមានសុវត្ថិភាពក៏ដូចជាសង្គតិភាពជាមួយគោលនយោបាយនានា ដែលរាជរដ្ឋាភិបាលបាន និងកំពុងតែដាក់ចុះ ៕





**៣កុំ** ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ១២

**សេចក្តីប្រកាសព័ត៌មាន អំពីលទ្ធផល ...**

បត្តិការបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ និងកិច្ចសហការបង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ជាមួយនឹងការរៈបរសាទរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងបី ក្នុងរយៈពេលកន្លងមក សម្តេចក្រឡាហោម **ស ខេង** ឯកឧត្តម នាយឧត្តមសេនីយ៍ **ទិល័យ ឡាខាំហ្វង** និងឯកឧត្តម ឧត្តមសេនីយ៍ឯក **តូ ឡឹម** ក៏បានផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក អំពីសភាពការណ៍ទូទៅនៅក្នុងតំបន់ និងសកលលោក ព្រមទាំងបានឯកភាព បន្តបង្កើនការយកចិត្តទុកដាក់លើការងារសំខាន់ៗមួយចំនួនទៀតផងដែរ ។





សូមជម្រាបជូនថា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីកម្ពុជា-ឡាវ-វៀតណាម ត្រូវបានធ្វើឡើងដោយប្តូរវេនរៀងរាល់ ០២ឆ្នាំម្តង រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រសួងនគរបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិនិត្យនិងពង្រឹងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនានារវាងប្រទេសទាំងបី ៕



**ពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







តមកពីទំព័រ ២០

**កិច្ចប្រជុំដកពិសោធន៍ការងារគ្រប់គ្រង...**

ឆ្លាប់សង្គមក្នុងប្រទេសមួយអាចប្រព្រឹត្តទៅបានអាស្រ័យទៅលើការគ្រប់គ្រងលើបញ្ហាមួយចំនួនដែល **ទី១** ការគ្រប់គ្រងមនុស្សបានល្អគឺជាដើមចមនៃសន្តិសុខជាតិ **ទី២** គ្រប់គ្រងមធ្យោបាយយានយន្តធ្វើដំណើរ **ទី៣** ការគ្រប់គ្រងមុខរបរនិង **ទី៤** គឺកាគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាសង្គម ។

ដោយឡែកបញ្ហាប្រឈមក្នុងការ ងារគ្រប់គ្រងជនបរទេសនៅព្រះរាជាណាចក្រកម្ពុជា មាន៤សំខាន់ ក្នុងនោះ **ប្រឈមទី១** គឺអ្នកដឹកនាំតាមថ្នាក់ខ្វះការទទួលខុសត្រូវ ខ្វះការយកចិត្តទុកដាក់ដូច្នេះក្រោយទទួលបានអនុសាសន៍ណែនាំនេះស្នងការនគរបាលទាំង ២៥ រាជធានី-ខេត្ត ត្រូវតែទទួលអនុវត្ត និងបែងចែកភារកិច្ចបន្តដើម្បីយកទៅអនុវត្ត ។ រីឯបញ្ហា **ប្រឈមទី២** គឺ មន្ត្រីជំនាញឯកទេសប្រើប្រាស់កម្មវិធី ឧបករណ៍ទំនើបដែលទាមទារអោយអ្នកប្រើប្រាស់ចាំបាច់ទំនើបដែរគឺ ត្រូវទទួលការហ្វឹកហាត់បន្ថែមចំណុចដែលខ្វះខាត ។ **ចំណុចទី៣** ជនបរទេសដែលមានគំនិតមិនស្មោះត្រង់អាជ្ញាធរចាំបាច់ត្រូវធ្វើការអប់រំហើយបើមិនស្តាប់ត្រូវចាត់វិធានការរដ្ឋបាល និងដាក់ពិន័យ ប៉ុន្តែបើនៅតែមិនស្តាប់ទៀតត្រូវចងក្រងឯកសារទៅតាមច្បាប់ ។ **បញ្ហាប្រឈមទី៤** គឺពាក់ព័ន្ធទៅនឹងអាជ្ញាធរមានសមត្ថកិច្ចដែលឃុបឃិតជាមួយគោលដៅ ជាមួយទីតាំងដែលជនបរទេសប្រព្រឹត្តបទល្មើសប្រឈមបើរកឃើញមានបែបនេះគឺត្រូវតែអនុវត្តតាមច្បាប់ ។

គួរបញ្ជាក់ថា ៖ តាមរបាយការណ៍ស្តីពីលទ្ធផលនៃការងារគ្រប់គ្រងវត្តមានជនបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជាបានអោយដឹងថាក្រោយពីទទួលបានការបណ្តុះបណ្តាលរួចហើយ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តទាំងអស់បានស្នើសុំមកអគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីបង្កើតគណនីជូនមន្ត្រីជំនាញ និងមន្ត្រីនគរបាលនៅតាមប៉ុស្តិ៍រដ្ឋបាលឃុំ-សង្កាត់ សរុបចំនួន ៤១០០ករណី ដើម្បីប្រើប្រាស់ក្នុងការតាមដានគ្រប់គ្រងជនបរទេសនៅក្នុងមូលដ្ឋានរបស់ខ្លួន ។ ជាមួយគ្នានោះមន្ត្រីនគរបាលបានចុះធ្វើការផ្សព្វផ្សាយ និងណែនាំដល់ម្ចាស់ទីតាំងលំនៅដ្ឋានដែលមានជនបរទេសស្នាក់នៅអោយចុះឈ្មោះបង្កើតគណនីដើម្បីរាយការណ៍ពីវត្តមានជនបរទេសស្នាក់នៅទីតាំងរបស់ខ្លួន ។

ជាលទ្ធផលមកដល់ខែ មករា ឆ្នាំ ២០២២ កន្លងមកនេះ មានម្ចាស់អ្នកកាន់កាប់លំនៅដ្ឋានបានស្នើបង្កើតគណនីសរុបចំនួន ៧១,៩៥៥គណនី ហើយបានរាយការណ៍ពីវត្តមានជនបរទេសក្នុងប្រព័ន្ធសរុបចំនួន៣៨៧,៨៣១នាក់ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

តមកពីទំព័រ ៤៣

**អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ...**

-ចុះត្រួតពិនិត្យចំណុចខ្វះចន្លោះការអនុវត្តតួនាទីរបស់មន្ត្រីនគរបាលចរាចរណ៍ របស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

-តាមដានមន្ត្រីរាជការក្រោមឱវាទក្រសួងមហាផ្ទៃដែលកំពុងបំពេញការងារជាមេធាវីផង និងជាមន្ត្រីរាជការផង

-ធ្វើការតាមដាន និងបានវិភាគការដាក់ទណ្ឌកម្មខាងវិន័យមន្ត្រីក្រោមឱវាទក្រសួងមហាផ្ទៃ ដែលត្រូវទទួលរង និងត្រៀមទទួលរងការដាក់វិន័យបានគេចវេះពីការអនុវត្តវិន័យ ដោយផ្ទេរភារកិច្ចចេញទៅអង្គភាពផ្សេង ក្នុងនោះមន្ត្រីខ្លះទទួលបានការតែងតាំង និងដំឡើងឋានន្តរស័ក្តិថែមទៀត ។






## ព្យាបាល និងដាក់ធ្មេញមិនគិតថ្លៃ

**មន្ទីរពេទ្យ ១៦ ឧសភា** របស់នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

សូមជូនដំណឹងដល់កងកម្លាំងនគរបាលជាតិ និងប្រជាជនទូទៅទាំងអស់ឱ្យបានជ្រាបថា : **មន្ទីរពេទ្យ ១៦ ឧសភា** បានរៀបចំព្យាបាលធ្មេញដោយឥតគិតថ្លៃ ។

**ក្នុងនោះមាន :**

- **ដកធ្មេញ**
- **សំអាតធ្មេញ**
- **ប៉ះធ្មេញ**
- **ព្យាបាលធ្មេញ**

**ចំពោះ**មន្ត្រីនគរបាលជាតិគ្រប់អង្គភាពទូទាំងប្រទេសដែលចង់មកទទួលសេវាដាក់ធ្មេញមិនមានគិតថ្លៃអ្វីទាំងអស់ត្រូវមាន ***(អត្តសញ្ញាណប័ណ្ណនគរបាល)*** ។

***បញ្ជាក់: ដោយឡែកប្រជាជនទូទៅមានតំលៃដូចខាងក្រោម :***

*-តម្លៃធ្មេញធម្មតា ១គ្រាប់ ១០$ (តម្លៃទីផ្សារខាងក្រៅ ១គ្រាប់ ៣០$*

*-តម្លៃធ្មេញ Ceramic ១គ្រាប់ ៣០$ (តម្លៃទីផ្សារខាងក្រៅ១គ្រាប់ ៨០$*

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ : 092 645 171, 015 75 79 79*





## វេជ្ជបណ្ឌិត ញៀម សុខន

**បន្ទប់ពិនិត្យ-ពិគ្រោះនិងព្យាបាលជំងឺទូទៅ**

**- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ**

មានពិនិត្យអេកូសាស្ត្រពណ៌ផ្ទៃក :

- សរីរាង្គក្នុងពោះមាន: ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម។
- សរីរាង្គរោគស្ត្រី: ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោះ សរីរាង្គក្រពេញទាយ៉ូអ៊ីដ : ពកក

**- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល ២០ឆ្នាំ ។**

**បញ្ចុះតម្លៃ ១០%** សម្រាប់មន្ត្រីនគរបាលជាតិ





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរុហ៍) សង្កាត់វាលវង់ ខណ្ឌ៧ មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០ម៉ែត្រ)

ទូរស័ព្ទ: 097 2666 215 / 012 848 917







តមកពីទំព័រ ២៨

## ប្រកាសចូលកាន់មុខតំណែង នាយក ...

នោះទៀតក្រសួងមហាផ្ទៃ បានយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល តាំងពីពេលបង្កើតក្រសួងមហាផ្ទៃឆ្នាំ១៩៨៣មកម្ល៉េះ។ ជាក់ស្តែងនៅពេលបង្កើតក្រសួងមហាផ្ទៃហើយនោះ **សម្តេច** ក៏ត្រូវបានគណបក្ស និងរាជរដ្ឋាភិបាល ផ្តល់សេចក្តីទុកចិត្តឱ្យធ្វើជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាប់ពីពេលនោះ និងក៏បានយកចិត្តទុកដាក់គិតគូរអំពីការរៀបចំឱ្យមានសាលាជាតិរដ្ឋបាល ដោយបង្កើតសាលាភូមិន្ទរដ្ឋបាល ដែលនៅក្បែរក្រសួងមហាផ្ទៃ មកដល់សព្វថ្ងៃនេះ ។ **សម្តេច** បន្តថា « ក្រោយមកយើងក៏បានប្រគល់សាលាភូមិន្ទរដ្ឋបាលនេះឱ្យទីស្តីការគណៈរដ្ឋមន្ត្រីគ្រប់គ្រង និងចុងក្រោយក៏ត្រូវបានប្រគល់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ » ។



**ស ម្តេ ច ក្រ ឡាហោម** បានបន្ថែមថា សាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលប្រកាសនាថ្ងៃនេះ បានដាក់គម្រោងរៀបចំសាងសង់អគារសិក្សា និងអគារអន្តេវាសិកដ្ឋាន មានទីតាំងនៅភូមិត្រពាំងវែង សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលគម្រោងនេះ អាចនឹងបញ្ចប់នៅក្នុងរង្វង់ឆ្នាំ២០២៤ ក្រោមកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA។

ពាក់ព័ន្ធកិច្ចការសំខាន់ៗចំពោះមុខ **សម្តេចក្រឡាហោម** ក៏បានផ្តល់អនុសាសន៍ឱ្យថ្នាក់ដឹកនាំសាលាជាតិរដ្ឋបាលមូលដ្ឋានយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រ ការបណ្តុះបណ្តាលបែបជាក់ស្តែងជាងទ្រឹស្តី និងយកចិត្តទុកដាក់រៀបចំបរិយាកាសល្អៗ និងប្រកបដោយគុណប្រយោជន៍ទិតទំពង្រឹងនិងអភិវឌ្ឍន៍ការងារស្រាវជ្រាវនានា ព្រមទាំងពង្រឹងកិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគី ។ ជាពិសេស សាលាជាតិរដ្ឋបាលមូលដ្ឋាន **ត្រូវគិតគូឱ្យបានរួចរាល់ពីឥឡូវនេះទៅពាក់ព័ន្ធនឹងការផ្តល់ការលើកទឹកចិត្តជូនសាស្ត្រាចារ្យ និងគ្រូបង្រៀន ដូចដែលបណ្ឌិត្យសភានគរបាលកម្ពុជាបានរៀបចំរួចរាល់ពាក់ព័ន្ធនឹងការផ្តល់តួនាទី និងកម្រិតថ្នាក់ជូនពួកគាត់ព្រោះថាការរៀបចំការងារនេះបានល្អនឹងអាចផ្តល់ឱកាសឱ្យសាលាជាតិរដ្ឋបាលមូលដ្ឋានមានទាំងនិរន្តរភាព ព្រមទាំងអាចប្រមូលបានអ្នកចេះដឹងមកចូលរួមបណ្តុះបណ្តាលមន្ត្រី ។**



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ឥត្ថិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

# កិច្ចប្រជុំស្តីពីការត្រៀមរៀបចំធ្វើសន្និសីទ អាស៊ានណាប៉ូល លើកទី ៤០ ដែលកម្ពុជា ធ្វើជាម្ចាស់ផ្ទះ





នាព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ កន្លងមកនេះ នៅទីស្តីការក្រសួងមហាផ្ទៃ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ឥត្ថិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំស្តីពីការត្រៀមរៀបចំធ្វើសន្និសីទអាស៊ានណាប៉ូល លើកទី៤០ (ASEANAPOL CONFERENCE 40th) ដែលព្រះរាជាណាចក្រកម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះ ចាប់ពីថ្ងៃទី០១-០៥ ខែមីនា ឆ្នាំ២០២២ ខាងមុខនេះ ។

កិច្ចប្រជុំស្តីពីការរៀបចំធ្វើសន្និសីទអាស៊ានណាប៉ូល លើកទី៤០ នាពេលព្រឹកនេះ មានការអញ្ជើញចូលរួមពីសំណាក់ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងឯកឧត្តម លោកជំទាវ ជាតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងអង្គភាព និងមន្ត្រីពាក់ព័ន្ធផងដែរ ។

ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ ក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកសមាជិកាទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ដើម្បីរួមគ្នាធ្វើយ៉ាងណាឱ្យការងាររៀបចំសន្និសីទអាស៊ានណាប៉ូល លើកទី៤០ ខាងមុខនេះ ប្រព្រឹត្តិទៅដោយរលូន និងទទួលបានជោគជ័យតាមការគ្រោងទុក។

គួររំលឹកថា សន្និសីទអាស៊ានណាប៉ូល លើកទី៣៩ (ASEANAPOL CONFERENCE 39th) បានប្រព្រឹត្តទៅក្រោមប្រធានបទ «ការលើកកម្ពស់ភាពជាដៃគូរក្សាបាននូវចំណងសាមគ្គីភាព» បានធ្វើឡើងនៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលពេលនោះវៀតណាមធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទ ៕



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ឯកឧត្តម អ៊ីច លាច អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ

បានការអនុញ្ញាតជាគោលការណ៍ពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ដើម្បីបំពេញកិច្ចការមួយចំនួនសំដៅត្រួតពិនិត្យប្រសិទ្ធភាពការអនុវត្តសេចក្តីណែនាំរបស់ក្រសួងដែលបានដាក់ចេញ និងការអនុវត្តតួនាទីភារកិច្ចរបស់មន្ត្រី និងអង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ ឱ្យស្របតាមច្បាប់ លិខិតបទដ្ឋានជាធរមាន ដើម្បីទប់ស្កាត់មន្ត្រីមួយចំនួនដែលឆ្លៀតឱកាសប្រើប្រាស់តួនាទីហួសដែនសមត្ថកិច្ចច្បាប់កំណត់ បង្កបាតុភាពឱ្យប្រជាពលរដ្ឋមានការថ្នាំងថ្នាក់ និងមិនសប្បាយចិត្ត ។

ឯកឧត្តម អគ្គាធិការ ក៏បានស្នើអគ្គាធិការរង និងប្រធាននាយកដ្ឋាន

# អគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ

## បើកកិច្ចប្រជុំត្រួតពិនិត្យសមាសភាពមន្ត្រី ដើម្បីចុះបំពេញភារកិច្ច



នៅសាលប្រជុំរបស់អគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ ព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ឯកឧត្តម **អ៊ីច លាច** អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំស្តីពីការណែនាំ និងចាត់មន្ត្រី ដើម្បីបំពេញភារកិច្ចចំពោះមុខ ។

ឯកឧត្តម អគ្គាធិការ បានមានប្រសាសន៍ជម្រាបពីគោលបំណងរបស់អង្គប្រជុំនាពេលនេះថា ៖ ដោយទទួលពិនិត្យសមាសភាព និងសមត្ថភាពមន្ត្រីរបស់ខ្លួន ដើម្បីចាត់ឱ្យចុះអនុវត្តការងារនេះតាមគោលការណ៍ដែលថ្នាក់ដឹកនាំក្រសួង ទើបបានអនុញ្ញាតរួមមាន ៖

☞ ៤១




## SK Teeth Whitening Powder

ជាប្រភេទឡេដុសធ្មេញឲ្យស សម្រាប់អ្នកដែលមិនមានពេលទំនេរច្រើន ។ ហើយក៏អាចប្រើជាមួយឈុត Home Kit សម្រាប់ប្រភេទធ្មេញល្បឿងខ្លាំងពីកំណើត ។ លក្ខណៈពិសេសរបស់វាគឺមានតួនាទីជួយសំអាតជាតិកំបោរលើធ្មេញបានយ៉ាងល្អ ។ ប្រើរយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




## SK Luxury Kit

ជាប្រភេទពន្លឺធ្វើអោយធ្មេញស ដែលមានមុខងារពិសេសៗ ជាច្រើនរួមបញ្ចូលគ្នាក្នុងប្រអប់ Luxury Kit តែមួយ ។ មានវីតាមីនជួយការពារធ្មេញ អញ្ចាញធ្មេញ និងការពារស្រៀវស្រគា។ Luxury Kit Design ឡើងយ៉ាងសាកសមបំផុតសម្រាប់មនុស្សសម័យថ្មី ថ្លៃថ្នូរជាមួយនិងបច្ចេកវិទ្យាទំនើប និងការវិចខ្ចប់ដ៏ស្រស់ស្អាត។ អាចធ្វើជាការជូនមនុស្សជាទីស្រលាញ់ ។ ប្រើប្រាស់រយៈពេល៧ថ្ងៃឃើញលទ្ធផល។




## Set Luxury + Powder

ឈុតពិសេសសំរាប់ធ្មេញល្បឿងខ្លាំងពីកំណើត

-ប្រើបាន ២៤ ដង
-គុណភាពសល្បើន គុណានិង២
-មានអនាម័យខ្ពស់ ការវិចខ្ចប់ខ្ពស់
-មានវិតាមីន C ការពារអញ្ចាញ
-មាន Florine ការពារធ្មេញពុក
-មាន Potassium nitrate ការពារស្រៀវ រី ស្រគាធ្មេញ
-ជួយធ្វើអោយធ្មេញភ្លឺរលោង សស្អាត កំចាត់កំនរកំបោរ និងស្នឹមខ្មៅៗ

លើធ្មេញប្រើរយៈពេល ៥ថ្ងៃ ចាប់ផ្តើមឃើញធ្វើប្លែក ។




## SK Home Kit Teeth Whitening

សម្រាប់ប្រភេទធ្មេញធម្មតាជាប្រភេទពន្លឺធ្វើអោយធ្មេញស ប្រើដោយខ្លួនឯងនៅផ្ទះ ដោយមិនចាំបាច់ចំណាយពេលវេលា Clinic សម្រាប់ប្រភេទធ្មេញល្បឿងធម្មតា មិនស្រៀវ មិនល្បឿងពីកំណើត ប្រើប្រាស់រយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។




## Madamk Menbrane Gel

ជួយផ្តល់សំណើមយ៉ាងល្អដល់ស្បែកមុខ
បំបាត់នូវបញ្ហា
-រមាស់ -ក្របាម -របកស្បែក -រលាក




## Madamk Healing Set Membrane Gel Add Oil

ជាប្រភេទឡេលាបថែរក្សា និង បំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចំរុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់រាល់បញ្ហារមាស់ក្របាមខ្លាំង របកស្បែករលាក ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និង ក្រាស់ឡើញវិញ ។




## Madamk Healing Set

ជាប្រភេទឡេលាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺមដ្ឋរលោង ការពារមុខជាំ អាចម៍រុយ និងជ្រួញ ហើយថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្របាមផងដែរ ។ លក្ខណៈពិសេសគឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នក ដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ ។

**ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឬស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839**




Madamk Aromatic Nourishing Face Oil

មានមុខងារ
-ជួយបំបាត់មុខក្រហម
-ជួយបំបាត់មុខស្តើងសរសៃក្រហម
-ជួយស្បែកមានជាតិទឹក ភ្លឺរលោងក្មេងជាងវ័យ
ចំពោះអ្នកមានអាយុលើសពី ៣០ឆ្នាំ ឡើងទៅប្រើ Oil
នេះរាល់ថ្ងៃវាជួយផ្តល់ជាតិទឹក អោយមុខក្មេងជាងវ័យ
និងពន្យាភាពចាស់ផងដែរ។

Madamk Hair Shampoo & Hair Conditioner

មុខងារ :
-ជួយបណ្តុះសក់
-ជួយព្យាបាលសរសៃសក់ដែលខូចខ្លាំង
-ជួយធ្វើអោយសក់ទន់រលោងក្រអូបនិងជួយអោយសក់រឹងមាំ
-លាងជំរះស្បែកក្បាលបានល្អ បំបាត់អង្គែ និងរមាស់




Madamk Advance Eye Essence

-ជាសេរ៉ូលាបភ្នែក វាមានតួនាទី២យ៉ាង ទី១
ព្យាបាល ទី២ បញ្ញាតភ្លាមៗ
-ជួយអោយភ្នែកបាត់ខ្មៅ បាត់ស្លក់ បាត់ជ្រួញ
-លាបភ្លាមឃើញភ្នែកអន់ខ្មៅ អន់ជ្រួញ អន់ស្លក់ភ្លាមៗ
២០-៣០% (លាងទឹកត្រលប់មកធម្មតាវិញ)
-លាបរយៈពេល ៣ខែឡើង ចាប់ផ្តើមឃើញលទ្ធផល
-លាបចូលអស់មិនកក លាបច្រើនយ៉ាងណាក៏មិនកក
និងអាចលាបនៅកន្លែងណាដែលមានស្នាមជ្រួញបានផលដែរ។




Madamk Qwhite Body Lotion

ជាឡេលាបខ្លួនអោយស្បែក ស មង្គរលោង
វាមានតួនាទី ៣យ៉ាង :
ទី១ បញ្ញាតអោយ ស ភ្លាម
ទី២ ធ្វើអោយស្បែក ស ពីខាងក្នុងពិតប្រាកដ
ទី៣ ជួយការពារកំម្តៅថ្ងៃបានយ៉ាងល្អ។
(លាងទឹកត្រលប់មកធម្មតាវិញ)
-លាបចាប់ពី ៣ខែ ឡើងទើបឃើញលទ្ធផល
ស្បែកសភ្លឺចេញពីក្នុង
-ស វែបស្បែកមានសុខភាពល្អ
-ជួយការពារកម្តៅថ្ងៃបានយ៉ាងល្អ SPF 25
រយៈពេល ៣ខែឡើងចាប់ផ្តើមឃើញលទ្ធផល







Madamk Herbal Cream ជា Cream

ផ្សំពីផ្កា ឬសឈើ និងម្សៅគុជខ្យងជួយ :
-បឺតជាតិពុល ជាតិថ្នាំគីមីពីក្រោមស្បែកមុខដែល
បន្សល់ពីផលិតផលចាស់
-បំបាត់អាល វីមុខ
-ជួយផ្ចិតរុនញើស
-ជួយអោយមុខភ្លឺរលោង






Madamk Healing Specail

ជាប្រភេទឡេលាបថែរក្សា និងបំប៉នស្បែកមុខ
វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ
អាចម៍រុយ ហើយជួយផ្តល់សំណើមដល់ស្បែក
និងជួយបំបាត់អាល វី មុនកប់ ជួយផ្ចិតរុញញើស
ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ
ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហម
បានផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយក
សារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពី
ផលិតផលចាស់ៗដែលមានសារធាតុថ្នាំ និងធ្វើអោយ
ស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ។

Madamk Armpit Scrub ជាសាប៊ូដុះពេលងូតទឹក
-ជួយបំបាត់ក្លិនក្លៀកភ្លាមៗក្រោយពេលងូតទឹករួច
-ជួយអោយក្លៀក ស មង្គ បាត់ងំពក មិនមានជាតិថ្នាំពេទ្យ
ដែលប៉ះពាល់ស្បែកក្លៀកទេ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839



# ប្រគល់–ទទួល ទីស្នាក់ការប៉ុស្តិ៍

## នគរបាលការពារព្រំដែន និងផ្ទះបាយ ជូនអង្គភាពនគរបាលការពារព្រំដែន

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ឧត្តមសេនីយ៍ឯក **ខូ ហាក់** ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ី សាគុណ** អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន បានដឹកនាំក្រុមការងាររៀបចំពិធីប្រគល់-ទទួលអគារប៉ុស្តិ៍នគរបាលការពារព្រំដែនគោក និងផ្ទះបាយដែលទើបសាងសង់រួច ផ្តល់ជូនវរសេនាតូចនគរបាលការពារ









៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:06 AM

ព្រំដែនគោកលេខ៦០៩ និងលេខ៦១១ នៃស្នងការដ្ឋាននគរបាល ខេត្តស្វាយរៀង ដោយមានការចូលរួមពី លោកឧត្តមសេនីយ៍ត្រី **អ៊ុក សំអឿន** ស្នងការរង តំណាង ឧត្តមសេនីយ៍ទោ **គឹម ឃន** ស្នងការនគរបាល ខេត្តស្វាយរៀង ។

គួរបញ្ជាក់ផងដែរថា៖ ប៉ុស្តិ៍នគរបាល និងផ្ទះបាយដែលរៀបចំប្រគល់-ទទួល ក្នុងពិធីនោះរួមមាន៖

-វរសេនាតូចនគរបាលការពារ



ឧត្តមសេនីយ៍ឯក ឌូ ហាក់ ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែន







ព្រំដែនលេខ៦០៩ ទទួលបានប៉ុស្តិ៍ចំនួន២ និងផ្ទះបាយចំនួន២( ប៉ុស្តិ៍ការពារព្រំដែនខ្សែត្រ និងប៉ុស្តិ៍ការពារព្រំដែនព្រៃវល្លិ៍) ។

-វរសេនាតូចនគរបាលការពារព្រំដែនលេខ៦១១ ទទួលបានប៉ុស្តិ៍ចំនួន២ និងផ្ទះបាយចំនួន២ ( ប៉ុស្តិ៍ការពារព្រំដែនបុសមន និងប៉ុស្តិ៍ការពារព្រំដែនថ្នាធ្នង់ ។

ដោយឡែកនៅព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២២កន្លងមកនេះ ឧត្តមសេនីយ៍ឯក **ឌូ ហាក់** ប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសព្រំដែននិង ឧត្តមសេនីយ៍ត្រី **ម៉ុន មាគាំ** ស្នងការនគរបាលខេត្តត្បូងឃ្មុំ បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលប៉ុស្តិ៍នគរបាលការពារព្រំដែនគោកចំនួន៤ និងផ្ទះបាយក្នុងអង្គភាពវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦១៥ និង៦១៧នៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ។

ប៉ុស្តិ៍នគរបាលការពារព្រំដែនគោកចំនួន៤ដែលត្រូវបានរៀបចំប្រគល់-ទទួលពេលនោះរួមមាន៖ ប៉ុស្តិ៍នគរបាលការពារព្រំដែនគោកអន្លង់ជ្រៃ ត្រាចខោល ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦១៥ និងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកសាទុំ និងថ្មតាដោក ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៦១៧ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងលោកជំទាវ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/sjtw/

SINCE 1997

WWW.SOKHAGROUP.COM
E: SOKHASUN@SOKHAGROUP.COM

Cell: 012 / 070 8 7777 6

SOKHA PRINTING HOUSE

#970, STREET BETONG, PHUM ROUNG CHAK,
SANGKAT PHNOM PENH THMEY, KHAN SEN SOK

WE KNOW,
WHAT YOU WANT

















MAGAZINE • CATALOGUE • MENU • BOOKLET • ANNUAL REPORT • DIARY • NOTEBOOK • BROCHURE • FLYER • CORPORATE IDENTITY • FOLDER • CALENDAR • PAPER BAG • PLASTIC BAG • ECO BAG • KEY CHAIN • HAND FAN • PARASOL/UMBRELLA • PEN • T-SHIRT • CAP • BAG • CAKE BOX • MEDICAL BOX • POSTER • BANNER • BILLBOARD • PRE-PAID CARD • ID CARD • CHEQUE • SECURITY CARD


VHP
VHP Global Co., Ltd.
ទឹកប៉ីធម្មជាតិ
ដើម្បីសុខភាព
ទិញឥឡូវនេះ ទទួលបាន
1 ឆ្នាំ
ធានាជូនសេវាកម្មបច្ចេកទេស
- ដឹកជញ្ជូនមិនគិតថ្លៃ
- ដំឡើងមិនគិតថ្លៃ
កង្ហារ Hatari
MODEL: W2-340S
MODEL: HWJ-110
MODEL: W2-320
MODEL: W2-340
HOT
COLD
4 FILTER FUNCTION
HWJ-110 13L
W2-320 10L
W2-340 27L
W2-340s 11L
W2-160p 10L
W2-320WH 9L
W2-320H 9L
W2-1000 10L
WH-UP 200 90L/H
HU-800 90L/H
មុខងារតម្រង់ 4 FILTER FUNCTION
Sediment
ច្រោះកករ (៣ខែប្តូរម្តង)
Pre -Carbon
ច្រោះសារធាតុគីមី (៦ខែប្តូរម្តង)
Post -Carbon
បង្កើនរសជាតិទឹក (៩ខែប្តូរម្តង)
UF -Membrane
កំចាត់មេរោគក្នុងទឹក (១២ខែប្តូរម្តង)
មេដាយទទួលស្គាល់ពី អាមេរិក អឺរ៉ុប និងកូរ៉េ
FDA
ISO 9001
ETL
ត្រូវការតំណាងលក់ផ្តាច់មុខតាមតំបន់នីមួយៗ
VHP Globle
www.hyundaiwater.com
023 6666 919 / 069 5000 86
HYUNDAI
WACORTEC
ម៉ាស៊ីនចម្រោះទឹក
ព័ត៌មានបន្ថែម
អាស័យដ្ឋាន : ផ្ទះលេខ ៣៨C ផ្លូវ ៤០៨ សង្កាត់ទួលទំពូង II ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល : info@vhp-global.com / facebook.com/vhp.global

22/5/23, 10:06 AM




# ការរាតត្បាតវីរុស បំប្លែងថ្មីអូមីក្រុង OMICRON

តាមការសិក្សាស្រាវជ្រាវពីអ្នកឯកទេសផ្នែកវេជ្ជសាស្ត្រក៏ដូចជាអង្គការសុខភាពពិភពលោកបានឱ្យដឹងថា វីរុសបំប្លែងថ្មីប្រភេទអូមីក្រុង(Omicron)មានការឆ្លងរីករាលដាលកំរិតខ្ពស់ និងឆាប់រហ័សបំផុត ។ ដោយសារតែបច្ចុប្បន្នរបស់នេះហើយបានជាវីរុសកូវីដ-១៩បំប្លែងថ្មីបានវាយលុកពិភពលោករបស់យើងបានយ៉ាងឆាប់រហ័សបំផុតដែលគេពុំធ្លាប់ឃើញមានការកើតឡើងក្នុងរយៈពេល១០០ឆ្នាំកន្លងមកនេះនៅពាសពេញពិភពលោក។

### ដូចម្ដេចទៅដែលគេហៅថាការបំប្លែងថ្មីប្រភេទអូមីក្រុង (Omicron)?

អង្គការសុខភាពពិភពលោក(WHO) ប្រើប្រាស់អក្ខរក្រមភាសាក្រិច ដើម្បីរៀបរាប់អំពីការពាក់ពន្ធ័នឹងការបំប្លែងថ្មីដែលវាចេញពី(SARS CoV 2) វាជាប្រភពនៃវីរុសបង្កឱ្យមាននូវជំងឺកូវីដ-១៩។



**គួរបញ្ជាក់ផងដែរថា** កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ វីរុសអូមីក្រុង ត្រូវបានគេចាត់ចូលក្នុងប្រភេទដែលមានលេខកូដ (B.1.1.529 ) ។ វីរុសកូវីដ-១៩បំប្លែងថ្មីប្រភេទអូមីក្រុង(Omicron)ត្រូវបានអង្គការសុខភាពពិភពលោកបង្ហាញក្ដីកង្វល់ ព្រោះថាការបំប្លែងថ្មីរបស់វាមានលក្ខណៈឆាប់រហ័សពេកស្ទើរតែមិននឹកស្មានដល់ ដែលធ្វើឱ្យប៉ះពាល់ដល់ឥរិយាបថ និងការប្រព្រឹត្តិរបស់មនុស្សទូទៅរហូតឈានដល់មានការផ្លាស់ប្ដូរទម្លាប់នៃការរស់នៅប្រាស្រ័យទាក់ទងគ្នាទាំងកំរិតអន្តរបុគ្គល សហគមន៍ និងពិភពលោកទាំងមូល ។ មានភស្តុតាងជាច្រើនបានបង្ហាញថា វីរុសបំប្លែងថ្មីប្រភេទអូមីក្រុង(Omicron)មានការរាតត្បាតដ៏ឆាប់រហ័ស និងលឿនជាងការបំប្លែងប្រភេទដែលតា (Delta) នៅតាមបណ្ដាប្រទេសជាច្រើនជុំវិញពិភព



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/ 

22/5/23, 10:06 AM









លោក ជាពិសេសគឺការរាតត្បាតចូលដល់សហគមន៍តែម្តង ដែលពេលខ្លះល្បឿនចម្លងរបស់វាកើនលើសដល់ទ្វេដងបើប្រៀបធៀបជាមួយនឹងការបំប្លែងថ្មីផងទៀត ។ ទោះបីជាយ៉ាងណាក្តីហានិភ័យនៅតែមានកំរិតខ្ពស់ជាងវីរុសបំប្លែងថ្មីមុនៗទៅទៀត ។

**តើការវិវត្តនៃវីរុសបំប្លែងថ្មីអូមីក្រុន (Omicron)កើតឡើងដោយរបៀបណា?**

នៅពេលដែលវីរុសកំពុងតែធ្វើគោចរ (ចម្លងពីមួយទៅមួយ) យ៉ាងទូលំទូលាយ និងការបង្កហេតុដែលញុំាងការរាតត្បាតពីវីរុសប្រភេទថ្មីមានការកើនឡើងឥតគណនា ។ តាមការសិក្សាស្រាវជ្រាវបានបង្ហាញបន្តទៀតថា ភាវៈរស់នៃវីរុសនេះចម្លងកើនឡើងល្បឿនរហ័ស ដែលជាសញ្ញាណរំលឹកដល់មនុស្សជាតិនៅពាសពេញភពផែនដី ថាការរាតត្បាតពីកូវីដ-១៩នៅតែបន្តកាន់តែរសាត់ឆ្ងាយទៅៗ ស្ទើរតែគ្រប់គ្រងវាលែងបានទៅហើយ ។ ស្ថិតនៅក្នុងហេតុការណ៍សុខភាពចំពោះមុខបែបនេះក្រុមអ្នកឯកទេសផ្នែកវិស័យសុខភាពសាធារណៈ បានលើកឡើងថាអ្វីដែលសំខាន់នោះ ពោលគឺ ប្រជាពលរដ្ឋត្រូវតែទទួលវ៉ាក់សាំងឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន រួមទាំងកិច្ចការពារផងទៀតក្នុងការបន្ទុចបន្ទាក់កុំឱ្យវីរុសបំប្លែងថ្មីរាតត្បាតឆាប់រហ័សពេក ។ និយាមស្នូលមួយចំនួនដែលពលរដ្ឋមិនត្រូវមើលរំលងនោះពោលគឺ ការរក្សាគម្លាតសុវត្ថិភាពឬគម្លាតសង្គមពាក់ម៉ាស់ជាប្រចាំថ្ងៃ លាងដៃនឹងសាប៊ូឱ្យបានញឹកញាប់បំផុតត្រូវទៅកាន់ទីតាំងដែលមានខ្យល់អាកាសចេញចូលបានស្រួលបួល ។

រឿងវ៉ាក់សាំងបានក្លាយទៅជាសារវន្តសំខាន់មួយសម្រាប់សកលលោកបន្ទាប់ពីការប្រើប្រាស់យន្តការសុខភាពសាធារណៈ មានដូចជាងាយស្រួលក្នុងការទទួលព័ត៌មានអំពីការវិវត្តចុងក្រោយនៅគ្រប់ទីកន្លែង ។ វិសមភាព (ភាពមិនស្មើគ្នា) លើការចែកចាយវ៉ាក់សាំងបានធ្វើឱ្យមានការប៉ះពាល់ដល់ប្រទេសក្រីក្រ

☞ ៥៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/sjtw/

22/5/23, 10:06 AM






តមកពីទំព័រ ៥២

**ពិភពលោក ដោះស្រាយបានទេ ជុំវិញ...**

មានចំណូលទាប ដែលក្នុងនោះភាគច្រើនជាក្រុមប្រទេសដែលស្ថិតនៅក្នុងតំបន់អាហ្វ្រិក ម្យ៉ាងទៀតអង្គការសុខភាពពិភពលោកធ្លាប់បានលើកឡើងដែរថា ប្រទេសដែលមានការផ្គត់ផ្គង់បានគ្រប់គ្រាន់និងល្អប្រសើររួចហើយ គួរតែចែករំលែកជាបន្ទាន់នូវវ៉ាក់សាំងទៅកាន់តំបន់អាហ្វ្រិកឱ្យបានច្រើនដូសតាមអ្វីដែលខ្លួនបានសន្យា ។ រហូតមកទល់នឹងបច្ចុប្បន្ននេះ វីរុសបំប្លែងថ្មីប្រភេទអូមីក្រុងបានវាយលុកស្ទើរតែពាសពេញសកលលោករួចទៅហើយ ខណៈដែលអង្គការសុខភាពពិភពលោកប្រកាសថារកឃើញវីរុសបំប្លែងថ្មីអូមីក្រុងកាលពីខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅ ។

**តើវីរុសបំប្លែងថ្មីអូមីក្រុង វាមានសភាពធ្ងន់ធ្ងរជាងវីរុសបំប្លែងថ្មីកូវីដ-១៩ ដទៃទៀតទេ ?**

តាមការរកឃើញពីដំបូងបានបង្ហាញថា វីរុសបំប្លែងថ្មីអូមីក្រុង( Omicron ) បានកាត់បន្ថយហានិភ័យឆ្លងសម្រាកនៅមន្ទីរពេទ្យទាបជាងវីរុសបំប្លែង( Delta )។ ប៉ុន្តែអង្គការសុខភាពពិភពលោក នៅតែព្រមានថាគេមិនគួរចាត់ទុកវាជាប្រភេទវីរុសស្រាលនោះទេ ចង់មិនចង់ប្រសិនណាបើមានការឆ្លងច្រើនអាចត្រូវគេរំពឹងទុកថានឹងមានការឆ្លងសម្រាកព្យាបាលនៅមន្ទីរពេទ្យក៏កាន់តែច្រើនឡើងដែរ ។ ម្យ៉ាងទៀត ប្រសិនណាបើមានការកើនឡើងនូវការឆ្លងចៀសមិនផុតទេដែលនាំឱ្យមានការប៉ះពាល់ដល់បុគ្គលិកសុខាភិបាល និងប្រព័ន្ធលំហែរទាំសុខភាពដែលជាលទ្ធផលចុងក្រោយការស្លាប់អាចនឹងកើនឡើងខ្ពស់ ។ វាជារឿងសំខាន់ណាស់ដែលរំលឹកពួកយើងជាទូទៅថាវីរុសបំប្លែងថ្មីកូវីដ-១៩នេះ អាចនឹងនាំឱ្យមានជំងឺធ្ងន់ធ្ងរ ឬក៏ស្លាប់ ខណៈដែលវីរុសបំប្លែងដែលតនៅបន្តគំរាមកំហែងនៅពាសពេញពិភពលោក ។

**គួររំលឹកផងដែរថា** គិតត្រឹមថ្ងៃសៅរ៍ ទី១២ ខែកុម្ភៈឆ្នាំ២០២២ វីរុសកូវីដ-១៩ បានឆ្លងរាតត្បាតដល់ទៅជាង ៤០០លានករណី ហើយខណៈដែលតួលេខអ្នកស្លាប់ដោយសារតែកូវីដ-១៩ ប្រមាណជាង ៥លាននាក់ នៅពាសពេញពិភពលោក ។ រីឯអ្នកជាសះស្បើយពីកូវីដ-១៩វិញមាន រហូតដល់ទៅជាង ៣២៩លាននាក់ ៕

ដោយ៖ អនុ.ទោ ប្រាក់ សម្ផស្ស



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/
Page 56 of 68



# បណ្តាំស្លឹកចាស់

- ដើមឈើព្រឹកព្រៃ ស្លឹកចាស់ដល់វ័យ ស្លឹកថ្មីផ្តើមលាស់
បែកត្រួយរហង់ គួរលង់សម្រស់ ទីទួលដងជ្រោះ
រស់ត៏ញ្ញាតិផៅ ។
- អនិច្ចាស្លឹកចាស់ ប៉ើងរាយដេរដាស មិនច្បាស់គោលដៅ
ជួនត្រូវខ្យល់គួច ហើបហើរបាត់ទៅ ពេលខ្លះជ្រកនៅ
ក្រោមម្លប់ស្លឹកខ្ចី ។
- កាលនៅជាប់មែក កិត្តិយសអនេក គាប់ភ្នែកគ្រប់វ័យ
បបោសអង្អែល ថ្នាក់ថ្នមរាល់ថ្ងៃ បំប៉នលកលៃ
ស្រោចទឹកដាក់ដី ។
- សម្លឹងព្រឹកល្ងាច តាមដានព្រោះខ្លាច ពួកសត្វយាយី
ធ្វើឱ្យខូចស្លឹក ព្រោះដង្កូវស៊ី ខ្វះទឹកខ្វះដី
សំភីគ្រប់ស្មៀត ។
- ស្លឹកមានវាសនា មនុស្សគ្រប់អាត្មា សរសើរស្រស់ស្អាត
គាប់ភ្នែកពេញចិត្ត ស្នេហ៍ស្និទឥតឃ្លាត លូតលាស់ព្រោងព្រាត
ជាទ្រព្យសំណព្វ ។
- ពិតណាស់ស្លឹកខ្ចី មនុស្សម្នាគ្រប់វ័យ ជ្រកកោនជាម្លប់
ផ្តល់គុណប្រយោជន៍ ទាំងថ្ងៃទាំងយប់ ប្រសើរសព្វគ្រប់
មានប្រយោជន៍ណាស់ ។
- កុំតូចចិត្តណា ពាក្យចាស់ពោលថា ស្នេហ៍ក្មេងភ្លេចចាស់
ធម្មជាតិផ្តល់មក ត្រូវតែប្តូរផ្លាស់ សន្និវាសធំណាស់
ឃើញច្បាស់គ្រប់វគ្គ ។
- គ្រប់គ្នាត្រូវចាំ គ្រោះកាចគ្រោះកម្ម នៅរង់ចាំអ្នក
ថ្ងៃនេះរូបខ្ញុំ ថ្ងៃក្រោយច្បាស់ជាក់ នោះគឺថ្ងៃអ្នក
ក្លាយជារូបខ្ញុំ ៕

ដោយ ជ.ស





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# មហាសង្ក្រាន្ត

## ឆ្នាំខាល ចត្វាស័ក

ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២ មហាសករាជ ១៩៤៤ ចុល្លសករាជ ១៣៨៤

## សុភមស្តុ! វរមង្គលាជយាគុបក

ព្រះពុទ្ធសករាជព្រះសាសនាអតិក្កន្ដាកន្លងទៅហើយបាន២៥៦៥ព្រឹមថ្ងៃអាទិត្យ ១៥កើត ខែពិសាខលុះដល់ថ្ងៃចន្ទ១រោច ខែពិសាខឆ្នាំខាលចត្វាស័កតទៅចូលពុទ្ធសករាជ២៥៦៦ ។

នឹងគណនាឆ្នាំខាលឥឡូវនេះ សង្ក្រាន្តចូលនៅថ្ងៃព្រហស្បតិ៍១៣កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស. ២០២២ វេលាម៉ោង១០:០០នាទី ។ ពេលនោះព្រះអាទិត្យចេញពីមីនរាសីទៅឋិតនៅមេសរាសីតាមផ្លូវគោវិថីគឺ ផ្លូវកណ្ដាល មានទេវធីតាមួយព្រះអង្គជាមគ្គនាយិកា ព្រះនាម **កិរិណីទេវី** ជារាជបុត្រីទី៥ នៃកបិលមហាព្រហ្មគង់នៅចតុម្មហារាជិកាទ្រង់អម្ពរពណ៌**បៃតងលម្អ**នៅព្រះការណ៍ដោយសៀតផ្កា**មន្ទារ** អាភរណៈ **កែវមរកត** ភក្សាហារទ្រង់ សណ្ដែក-ល្ង ព្រះហត្ថស្ដាំទ្រង់ **កង្វេរ** ព្រះហស្តឆ្វេងទ្រង់ **កាំភ្លើង** ទ្រង់គង់ឈរលើខ្នងដំរី(គជសារ)ជាយានពាហនៈ។ ទើបនាំអស់ទេវបុត្រទេវធីតាទាំងមួយ






**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

សែនកោដិហោះទៅកាន់គុហាកែវ**គន្ធមាលី** នាទីភ្នំកៃលាស់ ខេត្តហិមពាន្តជាទីតំកល់ទុកនូវព្រះសិរសា**កបិលមហាព្រហ្ម**ដែលតំកល់លើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជ តាមផ្លូវ ព្រះអាទិត្យ ចរចំនួន ៦០នាទី ។ ទើបនាំយកទៅតម្កល់ទុកកន្លែងដើមវិញ ហើយប្រជុំទេវបុត្រទេវធីតាទាំងមួយសែនកោដិចូលទៅស្រង់ទឹក **អនោតត្តមហាស្រះ** ដែលមានទឹកហូរចេញពីបំពង់ថ្មកែវ ដែលជាមាត់ **គោឧសភរាជ** ទាំង៧ត្រដាក់ក្បែរក្បាន្តព្រះរាជហឫទ័យ ហើយនាំគ្នាចូលទៅសមាទានរក្សាសីល ដោយសោមនស្សរីករាយគ្រប់ៗព្រះអង្គ ក្នុងភគវតីសភាសាលាដែលព្រះវិស្សុកម្មទេវបុត្រនិមិត្តថ្វាយ ដើម្បីបន្ទោបង់អពមង្គលឱ្យផ្ទះស្រឡះ ហើយចម្រើននូវសិរីសួស្តីជ័យមង្គលជន្មាយុយឺនយូរដល់ទេវតានិងមនុស្សសត្វផងទាំងឡាយ តាំងពីឆ្នាំថ្មីចូលមកនេះបានទូលំទូលាយសុខក្បែរក្បាន្តតរៀងទៅ ។

## មហាសង្រ្កាន្ត ឆ្នាំខាល ចត្វាស័ក

**ពុទ្ធសករាជ ២៥៦៦ មហាសករាជ ១៩៤៤ ចុល្លសករាជ១៣៨៤**

ថ្ងៃព្រហស្បតិ៍១៣កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស២០២២ វេលាម៉ោង១០:០០ នាទីព្រឹក ជាថ្ងៃចូលឆ្នាំខាលត្រីស័ក(ជាវារៈមហាសង្រ្កាន្ត)។

ថ្ងៃសុក្រ១៤កើតខែចេត្រត្រូវនឹងថ្ងៃទី១៥មេសា គ.ស២០២២ជាវារៈវនបត ។

ថ្ងៃសៅរ៍១៥កើត ខែចេត្រត្រូវនឹងថ្ងៃទី១៦ ខែមេសា គ.ស ២០២២ នៅវេលាម៉ោង១៣ និង៤៩នាទី ៤៨វិនាទី ជាវារៈឡើងស័កគម្រប់ជាសង្រ្កាន្តបីថ្ងៃគ្រប់បរិបូរណ៍ចូលជាសកលឆ្នាំខាល ចត្វាស័ក មហាសករាជ១៩៤៤ ចុល្លសករាជ១៣៨៤តទៅ ។

នៅក្នុងឱកាសសង្រ្កាន្តទាំងបីថ្ងៃ សូមអស់ប្រជាពលរដ្ឋប្រុសស្រីផងទាំងឡាយរៀបចំពលិការគ្រឿងសក្ការបូជាអុចប្រទីបធ្វាណា ថ្វាយព្រះរតនត្រ័យ និងទទួលស្វាគមន៍ទេវបុត្រទេវធីតាឆ្នាំថ្មី ហើយខំលះបង់ចិត្តអាក្រក់អន្យតិរ្ថីយជាចិត្តអប្រិយ៍ផាប់ ដោយគំនុំគុំគួនព្យាបាទឈ្នានីស ដែលកើតមានក្នុងឆ្នាំចាស់ឱ្យផ្ទះស្រឡះតាំងចិត្តប្រព្រឹត្តល្អ ប្រកបដោយមេត្តា ករុណា មុទិតា ឧបេក្ខា និងបញ្ញាធ្វើបុណ្យសុន្ទរ៍ទានតាមប្រពៃណី រក្សាសីលប្រាំឱ្យបានជាប់ជានិច្ច នោះទេវធីតានឹងឱ្យពរសព្ទសាធុការលោកអ្នកនឹងមានសិរីសួស្តី សុភមង្គលវិបុលសុខគ្រប់ប្រការតាំងពីឆ្នាំថ្មីនេះតរៀងទៅ ។

## រណ្តាប់ទទួលទេវតា

រណ្តាប់ទទួលទេវតាតាមទំនៀមពីបុរាណរៀងរហូតមក ត្រូវរៀបរានទទួលទេវតានៅខាងមុខផ្ទះមួយសម្រាប់តាំងគ្រឿងពលិការផ្សេងៗ ។ ត្រូវរៀបក្រាលសំពត់ពណ៌សហើយរៀបចំនូវគ្រឿងសក្ការបូជាទេវតា មានជាអាទិ៍បាយសី ៩ថ្នាក់មួយគូ បាយសី ៧ថ្នាក់មួយគូ បាយសី ៥ថ្នាក់មួយគូ បាយសី ៣ថ្នាក់មួយគូ បាយសី ប៉ាឆាមមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូ ទៀន៥ ធូប៥ លាច៥ ផ្កា៥ ដាក់លើជើងពាន១គូ ចេកនួន ចេកណាំវ៉ាដាក់លើជើងពានមួយគូផ្លែឈើ១១មុខ(១) រៀបដាក់ជើងពាន១១គូ ដូងឡៅមួយគូ ទឹកស្អាតពីរកែវ ។ ស្រេចហើយនៅវេលាម៉ោងដែលទេវតាចុះមកត្រូវជួបប្រជុំក្រុមគ្រួសារ ដើម្បីថ្វាយបង្គំព្រះនមស្សការព្រះរតនៈត្រ័យសមាទានសីល ហើយតាំងចិត្តឱ្យបានស្អាតបរិសុទ្ធ ផ្ទះស្រឡះនូវមន្ទិលទាំងពួងតម្កល់ចិត្តរំពឹងគិតទៅលើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរឭកលុះចប់ពិធីទទួលទេវតា ។

ចំពោះបាយសី ៩ថ្នាក់ ៧ថ្នាក់ ជាទំនៀមមានចែងនៅក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស និងមានអនុវត្តនៅព្រះបរមរាជវាំង តែចំពោះប្រជារាស្ត្រគួរធ្វើត្រឹម ៥ថ្នាក់ចុះមក ឬរៀបត្រឹមគ្រឿងសក្ការបូជាដែលមានទៀនប្រាំ ធូបប្រាំ ស្លាធម៌ កូនចេកមួយគូក៏ល្មមសមគួរដែរ ។ ចំពោះផ្លែឈើសម្រាប់ប្រជារាស្ត្រគួររៀបចំឱ្យបានត្រឹម៣ឬ៥មុខក៏ជាការប្រសើរ គឺទៅតាមធនធានរបស់ខ្លួន ។ នៅគ្រប់ដង្វាយទាំងអស់ត្រូវដាក់ផ្កាម្លិះភ្ជួងពីលើគ្រប់ដង្វាយនៅលើជើងពាន និងលើបាយសីត្រូវដោតទៀន ហើយដុតបំភ្លឺ ។

**ដកស្រង់ចេញពី ៖ មហាសង្រ្កាន្ត**

**គណៈកម្មការស្រាវជ្រាវវិជ្ជាហោរាសាស្ត្រ និង ប្រពៃណីទំនៀមទម្លាប់ខ្មែរ**



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



ឯកឧត្តម សន្តិបណ្ឌិត តេង សាវង្ស រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ



ឯកឧត្តម ទី ច័ន្ទផល រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ
អញ្ជើញអានបញ្ជីឈ្មោះបែងចែកក្រុមពិភាក្សា





តមកពីទំព័រ ០៦

## ក្រសួងមហាផ្ទៃ បូកសរុបលទ្ធផល...

សកលអាចបន្តវិវត្តប្រែប្រួលកាន់តែស្មុគស្មាញពិបាកប៉ាន់ស្មាន បណ្តាលមកពីការប្រកួតប្រជែងក្នុងចំណោមប្រទេសមហាអំណាចនានា ។ ទន្ទឹមនេះ ប្រទេសក្នុងតំបន់និងពិភពលោក ក៏នឹងបន្តជួបប្រទះបញ្ហាប្រឈមបណ្តាលមកពីវិបត្តិនៃជំងឺកូវីត-១៩ អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន សង្គ្រាមស៊ីវិល និងការប្រែប្រួលអាកាសធាតុបន្ថែមទៀត ។

ចំពោះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏នៅបន្តជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធការតម្កល់ការប្តេជ្ញាចិត្ត និងការស្រុះស្រួលឯកភាពគ្នាក្នុងចំណោមក្រសួង-ស្ថាប័ននានា ក្នុងដំណើរការផ្ទេរមុខងារ ធនធាន និងការទទួលខុសត្រូវមុខងារ ធនធាន ដែលបានផ្ទេរ ប្រកបដោយស្មារតីទទួលខុសត្រូវ និងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបញ្ហាប្រឈមនេះអាចបង្កឱ្យមានផលប៉ះពាល់មកលើដំណើរការនៃការអនុវត្តកម្មវិធីជាតិ ១០ឆ្នាំ ដំណាក់កាលទី២នេះ។

របាយការណ៍ស្វាគមន៍ បានបញ្ជាក់ទៀតថា៖ ផ្អែកលើបញ្ហាប្រឈមខាងលើនេះ រួមទាំងទិសដៅការងារសំខាន់របស់ក្រសួងមហាផ្ទៃ អង្គសន្និបាតបានធ្វើការពិនិត្យពិភាក្សា រិះរកដំណោះស្រាយសមស្រប ជាមួយការប្តេជ្ញាចិត្តរួមគ្នាបន្តខិតខំពុះពារយ៉ាងប្តូរផ្តាច់ ដើម្បីថែរក្សាការពារសុខសន្តិភាព ឯករាជ្យ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ រក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមឱ្យបានល្អប្រសើរ ព្រមទាំងប្តេជ្ញាលើកកម្ពស់ស្មារតីការទទួលខុសត្រូវក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិ ជាបន្តទៀត ។

អញ្ជើញផ្តល់អនុសាសន៍ក្នុងពិធីនោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជំរុញឱ្យក្រសួងមហាផ្ទៃត្រូវបន្តរួមគ្នាថែរក្សាការពារសន្តិសុខ ស្ថិរភាពនយោបាយ ឯករាជ្យភាព បូរណភាពទឹកដីអធិបតេយ្យជាតិ ការពារព្រះមហាក្សត្រ ការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ បន្តជំរុញលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការពារ និង លើកស្ទួយសិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់ប្រជាពលរដ្ឋ និងការពង្រឹងនីតិរដ្ឋស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

បង្កើនការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយក្នុងសង្គមឱ្យបានល្អប្រសើរជាប់ជាប្រចាំ។ ត្រូវបន្តពង្រឹង និងលើកកម្ពស់យន្តការសហប្រតិបត្តិការ និងសម្រេចឱ្យបាននូវភាពជាដៃគូក្នុងតំបន់និងអន្តរជាតិ ដើម្បីបង្ការទប់ស្កាត់សកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែនគ្រប់ប្រភេទ បទល្មើស



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

បច្ចេកវិទ្យា ការចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ។ បន្តស្រាវជ្រាវ និងបង្ក្រាបទប់ស្កាត់ឱ្យបានដាច់ខាតនូវរាល់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ សកម្មភាព កុបកម្ម ការធ្វើវិទ្ធង្សនា និងវិច្ឆេទកម្មតាមគ្រប់រូបភាពក្នុងសង្គម ។

ទន្ទឹមនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មានប្រសាសន៍សង្កត់ធ្ងន់ថា ៖ "ខ្ញុំសូមរំលឹកឡើងវិញដល់អាជ្ញាធរ និងការរៀបចំព្រឹត្តិការណ៍នានា ក្នុងពេលដែលកម្ពុជា ទទួលធ្វើជាប្រធានប្តូរវេនរបស់អាស៊ានក្នុងឆ្នាំ២០២២នេះ ព្រមទាំងខិតខំរួមគ្នាធានាឱ្យដំណើរការរៀបចំការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ អាណត្តិទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខនេះ ដំណើរការប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាស សន្តិសុខ សុវត្ថិភាពល្អប្រសើរ ។ ទប់ស្កាត់រាល់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងកាត់ព្រំដែនគ្រប់ប្រភេទនិងបន្តពង្រឹងយន្តការគ្រប់គ្រងវត្តមានជនបរទេសក្នុងប្រទេស សហការស្រាវជ្រាវរកជនបរទេសដែលលួចជ្រៀតចូលស្នាក់នៅខុសច្បាប់ ស្នាក់នៅហួសរយៈពេលកំណត់ និងជនបរទេសជាប់ពាក់ព័ន្ធ ការប្រព្រឹត្តបទល្មើសនានា ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា។









កងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនការយកចិត្តទុកដាក់បន្តអនុវត្តជាប់មិនដាច់ប្រកបដោយភាពម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់នូវវិធានការបង្ការទប់ស្កាត់បង្ក្រាបអំពើចោរកម្ម,ប្លន់ប្រដាប់អាវុធ,ឃាតកម្ម,ល្បែងស៊ីសងខុសច្បាប់ ក្រុមក្មេងទំនើង សកម្មភាពបំផ្លិច បំផ្លាញធនធានធម្មជាតិនិងការកាប់ព្រៃឈើខុសច្បាប់ ការទន្ទ្រានកាន់កាប់ដីធ្លីខុសច្បាប់ ការនេសាទខុសច្បាប់ អាជីវកម្មរ៉ែខុសច្បាប់ អាជីវកម្មខ្សាច់ខុសច្បាប់ អាជីវកម្មជីកនិងដឹកដីខុសច្បាប់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទក្នុងសង្គម។ សហការរក្សាការពារសុវត្ថិភាពកិច្ចប្រជុំ ជាពិសេសត្រូវបន្តពង្រឹងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឱ្យបានសស្រាក់សស្រាំជាប់ជាប្រចាំ ដើម្បីបង្ការទប់ស្កាត់និងបង្ក្រាប ការចរាចរ ការជួញដូរ ការប្រើប្រាស់ ការលួចកែច្នៃផលិតគ្រឿងញៀនខុសច្បាប់ដែលមួយរយៈចុងក្រោយនេះកំពុងមានការកើនឡើងគួរ ឱ្យព្រួយបារម្ភស្របពេលដែលនិន្នាការនៃការផលិតការចរាចរជួញដូរគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ និងពិភពលោកកំពុងមានការកើនឡើង" ។

ត្រូវបន្តបង្កើនការគ្រប់គ្រងការចេញ-ចូលប្រទេស សំដៅបង្ការទប់ស្កាត់ជនបរទេសចេញចូលស្នាក់នៅខុសច្បាប់

ត្រូវបន្តខិតខំរួមគ្នាពង្រឹងការអនុវត្តវិធានការនានា របស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយបន្តជំរុញការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាវិធានការគន្លឹះភ្ជាប់ជាមួយការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣ការពារ ៣កុំ" ឱ្យបានជាប់ជាប្រចាំក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពសង្គម រួមទាំងនៅតាមទីកន្លែងបំពេញការងារនៃស្ថាប័នសាធារណៈគ្រប់ថ្នាក់ដែលនេះ គឺជារបៀបរបបនៃការរស់នៅ និងបំពេញការងារជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សកម្មភាពប្រតិភូ ស ម ន នាំយក

## ថវិកាផ្តល់ជូនដល់គ្រួសារសព សមាជិក-សមាជិកា ដែលទទួលមរណភាព និងបាត់បង់សមត្ថភាពការងារ



**ឧត្តមសេនីយ៍ឯក ស្អួន គឹមស៊ាន់** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ប្រគល់ថវិកា ស ម ន ជូនប្អូនស្រី សំអាត វ៉ាម៉ូនីត ត្រូវជាកូនសពលោកឧត្តមសេនីយ៍ត្រី លី សំអាត។

**ឧត្តមសេនីយ៍ទោ ឈុន ចាន់សុខា** ប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រប្រគល់ថវិកា ស ម ន ជូនដល់លោក សួត លន់ កូនសពលោកឧត្តមសេនីយ៍ទោ កែ សារ៉ុត។





**ឧត្តមសេនីយ៍ទោ ប្អួត សុធី** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ចាំង ស៊ីហួយ ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ លី ចាន់ដារ៉ា។

**ឧត្តមសេនីយ៍ទោ ភាត ចន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានអង្គភាពអន្តរាគមន៍ប្រគល់ថវិកា ស ម ន ជូនលោក កែវ សុធា ត្រូវជាកូនប្រុសលោកព្រិន្ទបាលឯក លឹម សួង មន្ត្រីចូលនិវត្តន៍។



សូមលំអោនកាយរំលែកទុក្ខយ៉ាងក្រៀមក្រំ ចំពោះមន្ត្រីនគរបាលជាតិ ដែលបានពលីជីវិតក្នុងបេសកកម្មនានានៃបុព្វហេតុជាតិ មាតុភូមិ និង សូមបួងសួងឲ្យវិញ្ញាណក្ខន្ធបងប្អូន ឆាប់បានទៅកាន់សុខគតិភព។



**ពាក់ព័ន្ធ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



**ឧត្តមសេនីយ៍ទោ ហ៊ិន សុធី** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ហុំ វិមុល ត្រូវជាកូនស្រីសពលោកអនុសេនីយ៍ទោ ទូច សុខន មន្ត្រីចូលនិវត្តន៍។



**ឧត្តមសេនីយ៍ត្រី ឡុង គីម** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពត ប្រគល់ថវិកា ស ម ន ជូនលោកស្រី ចាន់ សុភា ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក ឈឿម ប៊ុនធឿន ។



**ឧត្តមសេនីយ៍ត្រី សេង គឹមឃន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកណ្តាល ប្រគល់ថវិកា ស ម ន ជូនលោកស្រី សែម ផល ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក ហែម សារ៉ា ។

**ឧត្តមសេនីយ៍ត្រី ឃឹម ប៊ិនឃោ** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានភស្តុភារ និងសម្ភារបច្ចេកទេស ប្រគល់ថវិកា ស ម ន ជូនលោកស្រី ហម សាមឿន ត្រូវជាភរិយាសពលោកព្រិន្ទបាលឯក ឡៅ គឹមស៊ុន ។



**ឧត្តមសេនីយ៍ត្រី តូច សាកល** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តសៀមរាប ប្រគល់ថវិកា ស ម ន ជូនលោកស្រី ហ៊ុយ ងីម ត្រូវជាភរិយាសពលោកវរសេនីយ៍ឯក ឆេត ញ៉ា ។



**ឧត្តមសេនីយ៍ត្រី ស្រ៊ី សុវណ្ណ** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ប្រគល់ថវិកា ស ម ន ជូនលោកស្រី ប្រាក់ សុឃឿន ត្រូវជាភរិយាសពលោកអនុសេនីយ៍ទោ កុយ សារ៉ន ។





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



អ្នកស្រី
ប៉ាល់ វណ្ណារីរក្ស
រឿង
បំភ្លេចមិនបាន
ចំណាត់ថ្នាក់លេខ១ស្ទួន ពានរង្វាន់ព្រះសីហនុរាជ ឆ្នាំ១៩៩៥

តមកពីលេខ ១០២

នាងមិនចូលចិត្តឬកពារគ្មានសច្ចភាព ឬគេសំអាងលើទ្រព្យ ? ទុកបំណងរបស់នាងស្មើនឹងដុំដីដែលគេដើរជំពប់ជើងដែលគេមិនទាន់ទាត់ចោល ដោយគ្រាន់តែគេលោតលេងលេងជាបណ្ដើរដល់ចាំរសាត់ការសប្បាយនឹងលោតលេងនោះគេនឹងជាន់កំទិចឬទាត់ចោលតែម្ដង ។ មានហើយសំរាប់អ្នកមានអ្នកក្រដូចនាងពុំបាននាំលាភសក្ការៈជូនគេ...ការជួបគឺមានតែក្ដីរំខានពេលវេលាឬរំខានទ្រព្យគេតែប៉ុណ្ណោះ...ឱ!អ្នកមានអ្នកចាត់ទុកអ្នកក្រជាសំរាមចូលភ្នែកអ្នកឬអ្វីហ្នំ ?

អ្នកស្រីគ្រប់គ្រងផ្ទះ យល់ឥតសង្ស័យនូវការប្រែប្រួលទឹកមុខស្រីកំព្រា អ្នកស្រីញញឹមនិយាយទន់ភ្លន់ ៖

-ប្រហែលក្មួយកំពុងខឹងនឹង លោកប្រុសទេដឹង ។ បើសិនជាក្មួយដឹងរឿងពិតរវាង លោកប្រុស និងអ្នកនាង **ថាវរី** ក្មួយប្រាកដជាអាណិតពួកគាត់ជំនួសកំហឹងមិនខាន ។

-ខ្ញុំមិនខឹងទេ គ្រាន់តែអន់ចិត្តណាំមីង ។ ឯរឿងរបស់ពួកគាត់ខ្ញុំក៏មិនហ៊ានចង់ដឹងដែរ ព្រោះនាទីខ្ញុំជាមនុស្សក្រោកដោយសារម្ដាយគាត់ ។

-គឺរូបក្មួយតែម្ដង ដែលគួដឹង និងចាំបាច់សំរាប់ពេលនេះ ។ " អ្នកស្រីបន្ថែមសំដីលបមើលមុខស្រី " **ទីរិយា** នៅស្ងៀមឥតស្ដីនាងមើលមុខអ្នកស្រីដោយអាការឆ្ងល់អ្នកស្រីងកងក្ដើមងំទើបបន្ត :

-អ្នកនាង **ថាវរី** ជាមិត្តភក្ដិចិត្តមួយថ្លើមមួយរបស់លោកស្រី **សូនី** ដែលជាម្ដាយនាងតូច **តារី** ។ ក្រោយពីរៀបការលោកស្រីសូនីចាប់មានជំងឺជាញឹកញាប់ គាប់ជួនលោកប្រុសជាប់រវល់មមាញឹកជាមួយមុខជំនួញ គឺមានតែអ្នកនាង **ថាវរី** ដែលព្យាយាមចុះឡើង ដើម្បីថែរក្សា លោកស្រី **សូនី** ក្បិតកាលណោះ លោកប្រុសពុំទាន់មានជីវភាពស្ដុកស្ដមដូចសព្វថ្ងៃទេ លោកប្រុសខិតខំប្រឹងប្រែងរកទ្រព្យសំរាប់គ្រួសារជាខ្លាំង ម្យ៉ាងទាំង លោកប្រុស និងលោកស្រី ជាបងប្អូនជីដូនមួយដែលកំព្រាឪពុកម្ដាយ សាច់សារលោហិត ព្រោះរបបពលឆ្នាំ៨ខែ ។ ក្រោយមកអ្នកនាង **ថាវរី** បានទៅបន្តការសិក្សាឯបរទេសចំនួន៥ឆ្នាំ ។ នៅពេលអ្នកនាងថាវរីត្រឡប់វិលមកមាតុភូមិវិញ អ្នកស្រី **សូនី** បានលាចាកលោកចោលនាងតូច និងឪពុកវា...លោកប្រុស និងអ្នកនាង **ថាវរី** អាណិតស្រឡាញ់ថ្នាក់ថ្នមកូនតូចរហូតវាក្លាយជាក្មេងទំរើសរឹងរូសជាទីបំផុត ។

-អូហ៍ ការពិត អ្នកនាង **ថាវរី** ជាភ្ញៀវពិសេសរបស់លោកប្រុសទេតើ ។

-នៅមានរឿងពិសេសដែលកាន់តែគួរឱ្យអាណិតពួកគាត់...ហ៊ឺ ។

-អ្នកមីង តើជារឿងអ្វីទៅ ? ខ្ញុំអាចដឹងបានឬទេ ? " ងីតាប្រែមុខពីឆ្ងល់មកស្រពោនលាយឆ្ងល់ "

-មិនមិនណាក់ទេ...ដូចជាក្មួយឃើញហើយ អ្នកនាង **ថាវរី** ជានារីទន់ភ្លន់ វាងវៃ និងប្រកបដោយចិត្តសប្បុរសមានមេត្តាធម៌ជានិច្ច ចំពោះនាងតូច **តារី**...អ្វីៗវាជាស្ពានដួងចិត្តភ្ជាប់ចំណងស្នេហ៍ដល់ឪពុកក្មេង ។ ប៉ុន្តែព្រហ្មលិខិតចេះតែតាមដាក់ទណ្ឌកម្មដល់លោកប្រុស...ស្នេហាអ្នកទាំងពីរមិនអាចបង្កើតអាពាហ៍ពិពាហ៍បានទេព្រោះ..."គាត់អ្នកដើមកនិយាយលែងចេញ "

-ព្រោះអី អ្នកមីង?ឬមួយ អ្នកនាង **ថាវរី** មានឋានៈនិងទ្រព្យធនទាបជាង លោកប្រុស ?

-ខុសហើយក្មួយចិត្ត លោកប្រុសគ្មានការប្រកាន់ឋានៈឡើយ សោតឯសម្បត្តិទ្រព្យអ្នកទាំងពីរមានប្រហាក់ប្រហែលគ្នា...អ្នកនាង **ថាវរី** ជាវិស្វករ និងជាប្អូនសេដ្ឋីម្នាក់ ឯលោកប្រុសជាអ្នកជំនួញដ៏កំពូល...ប៉ុន្តែ លោកប្រុសស្រឡាញ់កិត្តិយសអ្នកនាង **ថាវរី** គោរពគុណបងប្រុស ។

-កិត្តិយស និងគុណបងប្រុស សុទ្ធសឹងជាគុណធម៌ដ៏ល្អទេតើអ្នកមីង គួរអីមានបញ្ហាចោទ ?

-បញ្ហាវាមាន! លោក **ថាវរិន** ជាបងប្រុស អ្នកនាង **ថាវរី** គេនោះជាមនុស្សចង្អៀតចង្អល់ ច្រណែនឈ្នានីសអ្នកដទៃជាពិសេសចំពោះជនដែលមានរបរដូចគ្នា ។ លោកប្រុសព្យាយាមដកខ្លួនគេចពីជម្លោះក្នុងផ្លូវរកស៊ី ឯគេព្រយាមផ្ទិះកកាយ ក្បិតគេច្រណែននឹងកិត្តិយស លោកប្រុស ។ ដើម្បីកាច់បំបាក់លោកប្រុស ហើយលោកប្រុសក៏មិនរណបគេ ។ ម្នាក់គោរពបងប្រុស ម្នាក់ស្រឡាញ់កិត្តិយស ស្នេហាពួកគេមានតែការឱបទុក្ខ និងកង្វល់ ។ ពួកគេស្រឡាញ់គ្នាថ្នមចិត្តគ្នា ដូចជាថ្នមប្រស្រីភ្នែក តែអាពាហ៍ពិពាហ៍ពួកគេមិនហ៊ានរំលឹក ។

-ជារឿងគួរឱ្យខ្លោចផ្សាណាស់អ្នកមីង...ពួកគាត់ជាអ្នកមានទ្រព្យធន តែ...ហ៊ឺ...

-ជីវិតវាអញ្ចឹង...សើច និងយំ នៅក្បែរគ្នា... មនុស្សម្នាក់មានរឿងសើច ឬរឿងយំមួយបែបណាក្មួយ ។

## ប្រលោមលោកវគ្គ៨

**តិរត្ន** កំពុងពិនិត្យបញ្ជីទំនិញក្នុងបន្ទប់ធ្វើការរបស់គេ ។ បុរសត្រូវមានកម្មវិធីជួប **ទីរិយា** នៅវេលាម៉ោង៧ ។ គេបិទសៀវភៅបញ្ជីដើបដើរមករកកៅអីពូកទន្លាក់ខ្លួនលើកជើងគងអន្ទាក់ខ្លាចោលនេត្រាសំឡឹងចំនាឡិកាដែលព្យួរនៅជញ្ជាំង ស្របពេលនាឡិកាគោះអន្លូងចំនួន៧ងងល្ងម...នេះជាពេលវេលាសប្រាប់ការជួបរវាង**នរៈ** និងអ្នកគ្រូរបស់ **តារី** ។ បុរសអភិជន ដក

តទៅលេខក្រោយ



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:06 AM








តមកពីទំព័រ ៣០

**កិច្ចប្រជុំបូកសរុប លទ្ធផលការងារ...**

១.៤៩៧នាក់ និងរបួស ចំនួន ៣.៦១៥នាក់ របួសធ្ងន់ ២.២៤៦នាក់ ។ អ្នកស្លាប់ភាគច្រើននៅរាជធានីភ្នំពេញ ចំនួន ២៤៥នាក់, ខេត្តកណ្ដាល ចំនួន ១៤១ នាក់ និងខេត្តកំពង់ចាម ចំនួន ៩៦នាក់ ។ រីឯមូលហេតុបណ្ដាលឱ្យមានគ្រោះថ្នាក់ គឺបើកបរលើសល្បឿនកំណត់៣៨%, មិនគោរពសិទ្ធិ ២៤%, មិនប្រកាន់ស្ដាំ ១៤%, វ៉ាជែង៨%, បត់៨%, ស្រវឹង៤%, ក្តាយានយន្ត៣% និងងុយ១% ។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ស.ច.គ បានមានប្រសាសន៍ថា៖ ជាទិសដៅយើងនឹងបន្តយុទ្ធនាការអប់រំផ្សព្វផ្សាយអំពីច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក នៅតាមរាជធានី-ខេត្តទាំង២៥ ព្រមទាំងចែកស្ទីកឃ័រចំណាំងផ្លាត និងមួកសុវត្ថិភាពជូនដល់អ្នកបើកបរទោចក្រយានយន្ត ។ ជាពិសេសបន្តរឹតបន្តឹងការអនុវត្តច្បាប់ ស្ដីពីចរាចរណ៍ផ្លូវគោក នៅគោលដៅដើមទីក្នុងកំពង់ផែស្វយ័តភ្នំពេញ និង កំពង់ផែស្វយ័តក្រុងព្រះសីហនុ ព្រមទាំងបន្តការងារត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសនៅតាមរាជធានី-ខេត្ត។

អញ្ជើញផ្តល់អនុសាសន៍ក្នុងឱកាសនោះ **សម្ដេចក្រឡាហោម** បាន



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/sjtw/








ប្រសាសន៍ថា ៖ ស្ថិតក្នុងបរិបទនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកនៅតែបន្តកើតមាន ហើយបានបន្សល់ទុកនូវសោកនាដកម្មជាច្រើនដល់ប្រជាពលរដ្ឋ ដូចជាការបាត់បង់ជីវិត ការរងរបួស ពិការភាព និងការខាតបង់ទ្រព្យសម្បត្តិ ដែលបង្កដោយអ្នកប្រើប្រាស់ផ្លូវមួយចំនួនដែលមិនគោរពប្រតិបត្តិច្បាប់ និងខ្វះសីលធម៌យោគយល់អធ្យាស្រ័យ ហាក់បីដូចជាមិនស្រឡាញ់ជីវិតខ្លួនឯង ឬជីវិត អ្នកដទៃ ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** បានផ្តល់អនុសាសន៍ឱ្យអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍រាជធានី-ខេត្ត ត្រូវបន្តជំរុញអនុវត្តកិច្ចការសំខាន់ៗ ដូចជា ៖ បន្តធ្វើការរឹតបន្តឹងអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយត្រូវមានវិធានការច្បាស់លាស់ ផ្តោតលើមូលហេតុមុខសញ្ញាគោលដៅ និងពេលវេលាដែលបានកើតឡើងនូវគ្រោះថ្នាក់ ឬ អំពើល្មើសច្បាប់។ ជាពិសេសត្រូវជំរុញការបំពាក់បរិក្ខារសុវត្ថិភាពលើផ្លូវថ្នល់រួមមាន ភ្លើងស្តុប ផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍នៅតាមផ្លូវថ្នល់ដែលរដ្ឋបាលរាជធានី-ខេត្តទទួលខុសត្រូវ ៕









៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

SOKIMEX INVESTMENT GROUP

# ក្រុមហ៊ុន សុគីមិច អ៊ិនវេសមេន គ្រុប
# SOKIMEX INVESTMENT GROUP CO., LTD.




#22 Kramuon Sar,Sangkat Phsar Thmey 2, Daun Penh, Phnom Penh Cambodia
Tel: (855) 23 998 918,Fax: (855) 23 998 920| E-mail: info@skmig.com | Website: www.skmig.com